*What is the Gospel?*

Copyright © 2012 by The Gospel Coalition

Published by Crossway
a publishing ministry of Good News Publishers
Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.
All rights reserved.

This project was accomplished in partnership with The Gospel Coalition International Outreach.

# តើអ្វីទៅគឺជាជំណឿងល្អ?
# (តើជំណឿងល្អគឺជាអ្វី?)

លោក ប្រាយអាន ឆែផែល Bryan Chapell

**មាតិកា**


ព្រះប្រទាននូវអ្វីដែលទ្រង់ត្រូវការ ............................................................3

ព្រះធ្វើឲ្យអ្វីដែលទ្រង់ផ្គត់ផ្គង់បានត្រឡប់ជាឥតខ្ចោះ ..................................10

ព្រះប្រើអ្នកណាដែលទ្រង់បន្សុទ្ធយ៉ាងឥតខ្ចោះ៥ ............................................17

កំណត់ ...........................................................................................19


នៅថ្ងៃមួយប្អូនប្រុសរបស់ខ្ញុំត្រូវបានប៉ូលិសចាប់ខ្លួន ប៉ុន្តែមានព្រឹត្តិការណ៍ជាច្រើនបានកើតឡើងអស់រយៈពេលជាច្រើនឆ្នាំមុននេះ ដែលជាហេតុ ទៅឲ្យមានការចាប់ខ្លួននេះកើតឡើង។ នៅពេលដែលគាត់កំពុងតែចំរើនវ័យធំឡើង ឃ្លាគួរសមមួយដែលគ្រួសាររបស់ខ្ញុំតែងតែប្រើដើម្បីបរិយាយអំពីសមត្ថភាពខាងសតិបញ្ញារបស់ប្អូនប្រុសរបស់ខ្ញុំគឺ «គាត់មានការលំបាកក្នុងការរៀនជាងមនុស្សភាគច្រើន»។ បើទោះជាសតិបញ្ញារបស់គាត់ពុំទាន់មានការអភិវឌ្ឍន៍ក៏ដោយ ក៏ដាវីឌ ប្អូនប្រុសរបស់ខ្ញុំ មានកំលាំង និងចិត្តរឹងមានៈកាន់តែខ្លាំងឡើងៗ នៅក្នុងខណៈពេលដែលឪពុកម្តាយរបស់ខ្ញុំមានវ័យកាន់តែចាស់ទៅៗ។ ភាពតានតឹងដែលកើតឡើងពីការដោះស្រាយបញ្ហានៅក្នុងជីវិតរបស់ដាវីឌ បូករួមនិងបញ្ហាផ្ទាល់របស់ពួកគាត់ផ្ទាល់ បាននាំឲ្យឪពុកម្តាយរបស់ខ្ញុំបែកបាក់គ្នា ហើយការនេះរឹតតែនាំឲ្យមានទុក្ខលំបាកកាន់តែធ្ងន់ធ្ងរជាងមុនក្នុងការថែរក្សាប្អូនប្រុសរបស់ខ្ញុំ ។ ក្នុងនាមជាមនុស្សពេញវ័យ សេចក្តីប្រាថ្នារបស់ដាវីឌក្នុងការធ្វើជាម្ចាស់លើខ្លួនឯង ហើយនិងអសមត្ថភាពខាងសតិបញ្ញារបស់គាត់ នៅតែជារឿងមួយដែលគួរឲ្យព្រួយបារម្ភ។ ដើម្បីមិត្តភាព និងការរំភើបចិត្ត គាត់បានសេពគប់ជាមួយនិងមនុស្សដែលនាំឲ្យគាត់មានបញ្ហា។

ដោយសារសតិបញ្ញារបស់គាត់អន់ គាត់មិនអាចយល់ថាហេតុអ្វីបានជាគាត់ត្រូវប៉ូលីសចាប់ខ្លួន ហើយជាប់ឃុំឃាំងបែបនេះ នោះទេ។ គាត់មានការភិតភ័យយ៉ាងខ្លាំង ហួសប្រមាណ ចំពោះការរស់នៅក្នុងបន្ទប់ឃុំឃាំង ដោយសារគាត់មានសតិបញ្ញាដូចកូនក្មេងអញ្ចឹង។ គាត់បានអង្គុយអោបក្បាលជង្គង់នៅឯជ្រុងម្ខាងក្នុងបន្ទប់ឃុំឃាំងដោយញ័រខ្លួនចំប្រប់។ ការភ័យខ្លាចរបស់ប្អូនប្រុសខ្ញុំបានជំរុញឲ្យបុរសម្នាក់ទៀតនៅក្នុងបន្ទប់ឃុំឃាំងជាមួយគាត់ ចែកចាយនូវព្រះរាជសារនៃសេចក្តីមេត្តាករុណារបស់ព្រះជាមួយដាវីឌ៖ «ព្រះយេស៊ូវអាចជួយអ្នកបាន។ សូមទុកចិត្តលើទ្រង់ចុះ»។

ដាវីឌនឹកចាំអំពីសេចក្តីពិតក្នុងមេរៀនដែលគាត់បានរៀន នៅក្នុងថ្នាក់ថ្ងៃអាទិត្យសំរាប់ក្មេងដែលអសមត្ថភាពខាងសតិបញ្ញា ដែលគាត់បានទៅចូលរួមរៀនកាលពីនៅក្មេង។ គាត់បានអធិស្ឋានសូមព្រះឲ្យអត់ទោសដល់គាត់ ហើយថែមទាំងជឿទុកចិត្តលើព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់គាត់។

ដាវីឌនឹងជាប់គុកអស់រយៈពេលយ៉ាងយូរ។ គាត់ក៏នឹងនៅជាប់ជាមួយព្រះយេស៊ូវជារៀងរហូតផងដែរ ទាំងទទួលបាននូវការអត់ទោស ការស្តារឡើងវិញ ការឲ្យតម្លៃ និងការបំផ្លាស់បំប្រែជាថ្មី។ នេះគឺជាដំណឹងល្អសំរាប់ប្អូនប្រុសរបស់ខ្ញុំ និងសំរាប់មនុស្សទាំងអស់ដែលជឿទុកចិត្តលើព្រះយេស៊ូវ។

ព្រះគម្ពីរប្រើពាក្យ «ដំណឹងល្អ» ដើម្បីសំដៅទៅលើព្រះរាជសារដែលព្រះបានបំពេញសំរេចតាមសេចក្តីសន្យារបស់ទ្រង់ក្នុងការបញ្ជូនព្រះអង្គសង្គ្រោះមួយអង្គដើម្បីឲ្យយាងមកសង្គ្រោះមនុស្សលោក ស្តារសិរីល្អរបស់ស្នាព្រះហស្តទ្រង់ឡើងវិញ ហើយនឹងគ្រប់គ្រងលើទាំងអស់ដោយសេចក្តីមេត្តាករុណា និងយុត្តិធម៌។ ហេតុនេះ យើងអាចសង្ខេបដំណឹងល្អបានយ៉ាងត្រឹមត្រូវថា «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកិយដើម្បីនឹងសង្គ្រោះមនុស្សមានបាប» (១ធីម៉ូថេ ១:១៥)។[១]

ការសង្គ្រោះ ការស្តារឡើងវិញ និងការគ្រប់គ្រងរបស់ព្រះគឺសំរាប់ស្ថានភាពខាងព្រលឹងវិញ្ញាណរបស់យើង ប៉ុន្តែនេះមិនមែនជាដែនកំណត់ នោះទេ។ តាមរយៈព្រះយេស៊ូវគ្រីស្ទ ព្រះរបស់យើងរំដោះរាស្ត្ររបស់ទ្រង់ឲ្យរួចពីលទ្ធផលដ៏នៅអស់កល្បជានិច្ចនៃអំពើបាបរបស់មនុស្សជាតិ។ លទ្ធផលនៃអំពីបាបទាំងអស់នេះបានប៉ះពាល់ដល់គ្រប់យ៉ាងទាំងអស់។ សេចក្តីសង្គ្រោះរបស់យើង រួមមានយើង ប៉ុន្តែព្រះរាជសារនៃសេចក្តីសង្គ្រោះ មានអត្ថន័យទូលំទូលាយជាងនេះទៅទៀត។

មុនពេលយើងសិក្សាបន្ថែមអំពីសេចក្តីពិតដ៏អស្ចារ្យទាំងនេះ យើងត្រូវការទទួលស្គាល់ថា ព្រះគម្ពីរមិនប្រកាសអំពីសេចក្តីពិតទាំងនេះដើម្បីគ្រាន់តែធ្វើឲ្យយើងមានការ អស្ចារ្យក្នុងចិត្តប៉ុណ្ណោះ ទេ។ ព្រះបើកសំដែងសេចក្តីពិតទាំងនេះដើម្បីឲ្យមនុស្សមានបាបដូចជា ដាវីឌ អ្នក និងខ្ញុំអាចមានសេរីភាពដ៏នៅអស់កល្បជានិច្ចពីទោសនិងអំណាចរបស់អំពើបាបតាមរយៈការទុកចិត្តលើដំណឹងល្អដែលថា ព្រះយេស៊ូវ គឺជាព្រះអម្ចាស់ដែលបានយាងមកដើម្បីសង្គ្រោះយើង។ តទៅនេះ គឺជា ទិដ្ឋភាពសំខាន់របស់ដំណឹងល្អនេះ។

## *ព្រះប្រទាននូវអ្វីដែលទ្រង់ត្រូវការ*[២]

យើងប្រហែលជាមិនចូលចិត្តឲ្យអ្នកណាម្នាក់ហៅយើងថា «ពួកមនុស្សមានបាប» នោះទេ ជាពិសេសប្រសិនបើយើងប្រើពាក្យនោះដើម្បីសំដៅទៅលើ ពួកឃាតករ និងពួកអ្នករំលោភកូនក្មេងតែប៉ុណ្ណោះ។ ប៉ុន្តែព្រះគម្ពីរនិយាយថា ព្រះពិតជាបរិសុទ្ធ ហើយអស់អ្នកដែលមិនរស់នៅតាមខ្នាតដ៏ឥតខ្ចោះរបស់ទ្រង់ ត្រូវបានហៅថា «ពួកមនុស្សមានបាប» ដែលជាពាក្យដែលមានន័យថា ខុសនឹងខ្នាតរបស់ព្រះ។ ប្រសិនបើយើងធ្វើបាប បើទោះជាបាបតូច នោះក៏មានន័យថាយើងបានធ្វើខុសនឹងព្រះរាជបំណងរបស់ព្រះទៅហើយ (រ៉ូម ៣:២៣ យ៉ាកុប ២:១០)។ ទ្រង់បានបង្កើតយើងមកប្រយោជន៍ដើម្បីអោយយើងបានឆ្លុះបញ្ចាំងនូវលក្ខណៈដ៏បរិសុទ្ធរបស់ទ្រង់ (១ពេត្រុស ១:១៦)។ ដូច្នេះ កំហុសរបស់យើងមិនត្រឹមតែធ្វើឲ្យយើងឈឺចាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឲ្យខូចទំនាក់ទំនងរវាងយើងជាមួយព្រះផងដែរ (អេភេសូរ ៤:៣០)។

### *រូបអង្គ នៃព្រះ*

បញ្ហានៅក្នុងទំនាក់ទំនងរបស់យើងជាមួយព្រះចាប់ផ្តើមឡើងនៅពេលដែលលក្ខណៈរបស់មនុស្សយើងត្រូវបានបង្ខូចដោយសារតែអំពើបាបរបស់ឪពុកម្តាយដំបូងរបស់យើង (រ៉ូម ៥:១២)។ ចាប់តាំងពីអ័ដាមនិងអេវ៉ាមក មនុស្សទាំងអស់ដឹងថាខ្លួនបានធ្វើបាបចំពោះមនុស្សដែលខ្លួនស្រលាញ់ ធ្វើឲ្យអ្នកដទៃទៀតឈឺចាប់ ហើយមិនបានដើរតាមខ្នាត ដែលខ្លួនដឹងថាត្រឹមត្រូវ។ យើងទាំងអស់គ្នាស្គាល់សេចក្តីខ្មាស និងការស្តាយក្រោយ។ ទាំងនេះពិតជាឆ្លុះបញ្ចាំងឲ្យឃើញអំពីសេចក្តី

ពិតខាងព្រលឹងវិញ្ញាណ ដែលយើងអាចនឹងមិនដែលចាប់ភ្លឹកមើលទាល់តែសោះគឺថា យើងមានអារម្មណ៍ថាមានទោស ពីព្រោះយើងត្រូវបានបង្កើតមកឲ្យដូចជារូបអង្គនៃព្រះ ប៉ុន្តែយើងបរាជ័យក្នុងការរស់នៅបែបដូច្នោះ (រ៉ូម ៣:១០)។

យើងត្រូវបានបង្កើតមកឲ្យដូចជារូបអង្គព្រះ (លោកុប្បត្តិ ១:២៦-២៧)។ ទ្រង់បានសូនបែបយើងឲ្យដូចទ្រង់ដើម្បីឲ្យយើងអាចស្រលាញ់ទ្រង់ និងអ្នកដទៃទៀតដែលត្រូវបានបង្កើតមកក្នុងរូបអង្គ ទ្រង់ផងដែរ។ នៅពេលយើងធ្វើបាប នោះយើងកំពុងប្រឆាំងនឹងលក្ខណៈដើមរបស់យើង ហើយ ជ្រាលជ្រៅក្នុងជំរៅចិត្ត យើងទទួលស្គាល់ ថាយើងបានធ្វើខុស។ ទោសកំហុសដែលយើងមាន គឺជាសំឡេងខ្ទរនៃការឈឺចាប់នៅក្នុងចិត្តរបស់យើង ដែលកើតឡើងគ្រប់ពេលដែលអំពើបាបធ្វើឲ្យយើងដាច់ឆ្ងាយចេញពីទំនាក់ទំនងដែលយើងត្រូវមានជាមួយព្រះ។ ក្នុងការមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះ ទ្រង់តំរូវឲ្យយើងមានភាពបរិសុទ្ធ ប៉ុន្តែទាំងនិស្ស័យ និងសកម្មភាពរបស់យើងធ្វើឲ្យយើងដាច់ចេញពីទ្រង់។ តើយើងអាចដោះស្រាយបញ្ហានេះដោយរបៀបណា? យើងមិនអាចដោះស្រាយបញ្ហានេះបានទេ! យើងគឺជាស្នាព្រះហស្តដែលមិនឥតខ្ចោះ ហើយមិនអាចធ្វើឲ្យខ្លួនយើងបានបរិសុទ្ធ មិនខុសអីពីដៃភក់មិនអាចជូតអាវសឲ្យបនស្អាតអញ្ចឹងដែរ។

ព្រះគឺជាអង្គតែមួយដែលអាចដោះស្រាយនូវទំនាក់ទំនងរបស់យើងជាមួយទ្រង់បាន ហើយទ្រង់ធ្វើការនេះដោយប្រទាននូវភាពបរិសុទ្ធដែលទ្រង់ត្រូវការ។ ព្រះជាអ្នកចាប់ផ្តើមធ្វើការនេះមុន (១យ៉ូហាន ៤:១៩)។ តាមរយៈព្រះយេស៊ូវ ព្រះសង្គ្រោះយើងចេញពីលទ្ធផលនៃអំពើបាបរបស់យើង។ ទ្រង់ប្រទាននូវអ្វីដែលយើងមិនអាចផ្តល់ឲ្យខ្លួនឯងបាន ហេតុនេះហើយបានជា ពេលខ្លះយើងហៅការផ្តត់ផ្គង់របស់ទ្រង់ថា «ដំណឹងល្អនៃព្រះគុណ»។ ព្រះគុណមានន័យថា «អំណោយទាន» ជាអ្វីដែលត្រូវបានប្រទានឲ្យអស់អ្នកដែលមិនអាចផ្គត់ផ្គង់ឲ្យខ្លួនពួកគេបាន ប្រៀបដូចជាអាវសដែលត្រូវបានប្រគល់ទៅឲ្យអស់អ្នកដែលបានធ្វើឲ្យខ្លួនឯងប្រទាក់ភក់។

## ភាពបរិសុទ្ធរបស់ព្រះ

ព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ ពន្យល់យ៉ាងច្រើនអំពីរបៀបដែលទ្រង់ធ្វើឲ្យយើងបានបរិសុទ្ធ។ ព្រះនាម «យេស៊ូវ» មានន័យថា «អ្នករំដោះ» បេសកកម្មរបស់ទ្រង់ គឺមករំដោះ (ឬសង្គ្រោះ) យើងឲ្យរួចពីលទ្ធផលនៃអំពើបាបរបស់យើង។ ពាក្យបន្ថែម «គ្រីស្ទ» មិនគ្រាន់តែជានាមប៉ុណ្ណោះទេ តែគឺជាពាក្យដែល បរិយាយអំពីព្រះរាជបំណងរបស់ព្រះយេស៊ូវ។ ពាក្យនេះគឺជាងារដែលមានន័យថា «ព្រះអង្គដែលបានទទួលនូវការចាក់ប្រេងតាំង»។ ព្រះដ៏ជាព្រះវរបិតាបានចាក់ប្រេងតាំងឲ្យព្រះយេស៊ូវធ្វើជាបេសកជនពិសេសរបស់ទ្រង់ដើម្បីប្រទាននូវភាពបរិសុទ្ធរបស់ទ្រង់ឲ្យដល់មនុស្សជាតិ។ ជាច្រើនសតវត្សព្រះបានសន្យាតាមរយៈពួកហោរារបស់ទ្រង់ថា ទ្រង់នឹងបញ្ជូនព្រះអង្គដែលទ្រង់បានចាក់ប្រេងតាំង ឲ្យមកសង្គ្រោះប្រជារាស្ត្ររបស់ទ្រង់ (កិច្ចការ ៣:១៨-២០)។ ទោះបីជាយ៉ាងណាក៏ដោយ មនុស្សភាគច្រើនមានការភ្ញាក់ផ្អើលនៅពេលព្រះអង្គដែលបានទទួលនូវការចាក់ប្រេងតាំងបានយាងមកដល់ ហើយប្រកាសថាទ្រង់ គឺជាព្រះបុត្រារបស់ព្រះផ្ទាល់។

ព្រះយេស៊ូវបានយាងមកក្នុងរូបអង្គឥតខ្ចោះនៃព្រះ។ ទោះបើទ្រង់ជាព្រះក៏ដោយ ក៏ព្រះយេស៊ូវបានយកនិស្ស័យជាមនុស្ស (កាឡាទី ៤:៤-៥ ភីលីព ២:៦-១១)។ ទ្រង់គ្រឡប់ជាព្រះនៅក្នុងសាច់ឈាម។ ព្រះយេស៊ូវមានលក្ខណៈដូចជាយើងគ្រប់យ៉ាងទាំងអស់លើកលែងតែម៉្យាង៖ ទ្រង់គ្មានបាបសោះ (ហេព្រើរ ៤:១៥)។ ព្រះយេស៊ូវមិនត្រឹមតែមិនបានធ្វើខុសប៉ុណ្ណោះទេ ប៉ុន្តែដោយហេតុថា ទ្រង់បានចាប់ទំផ្ទៃរបស់នាងម៉ារាដែលជាស្ត្រីព្រហ្មចារិយដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ទ្រង់ក៏គ្មានសេចក្តីពុករលួយដែលមនុស្សជាតិមាននោះដែរ (ម៉ាថាយ ២:២០-២៣)។

ភាពបរិសុទ្ធរបស់ព្រះគ្រីស្ទសំរេចការពីរយ៉ាងសំរាប់យើង។ ទីមួយ បង្ហាញយើងអំពីរបៀបដែលយើងត្រូវរស់សំរាប់ព្រះអង្គ។ បើសិនជាជីវិតបានពេញទៅដោយសេចក្តីស្រលាញ់និងគ្មានភាពអាត្មានិយម នោះនឹងមើលទៅមានលក្ខណៈដូចជាជីវិតរបស់ព្រះយេស៊ូវដូច្នេះដែរ (១យ៉ូហាន ៣:១៦)។ តាមរយៈទ្រង់ យើងរៀនរស់នៅ ក្នុងជីវិតដ៏ពេញលេញជាមនុស្សដែលសម្រេចតាមព្រះរាជបំណងរបស់ព្រះ ជាមនុស្សពេញលក្ខណៈ ហើយមានសេចក្តីប្រកប ជាមួយនឹងព្រះ។ ប៉ុន្តែធ្វើដូច

ម្តេចទៅ បើយើងមិនមានកិរិយាបែបនេះ ហើយក៏មិនមានសេចក្តីប្រកបជាមួយនឹងព្រះផងនោះ? អញ្ចឹងយ៉ាងម៉េចវិញ? នោះយើងត្រូវការការផ្តត់ផ្គង់ទីពីរដែលហូរចេញពីភាពបរិសុទ្ធរបស់ព្រះយេស៊ូវ។ ការផ្គត់ផ្គង់ទីពីរនេះ មិនគ្រាន់តែបង្ហាញយើងអំពីរបៀបរស់នៅសំរាប់ព្រះប៉ុណ្ណោះទេ ប៉ុន្តែតាមពិតទៅ ជួយឲ្យយើងអាចរស់នៅជាមួយព្រះដោយសារព្រះយេស៊ូវបានបំពេញតាមខ្នាតរបស់ព្រះ។

## យុត្តិធម៌របស់ព្រះ

ភាពបរិសុទ្ធរបស់ព្រះយេស៊ូវបានធ្វើឲ្យទ្រង់ក្លាយទៅជាយញ្ញបូជាដ៏ឥតខ្ចោះសំរាប់អំពើបាបរបស់យើង។ នេះគឺជាព្រះរាជសារដែលព្រះគម្ពីរផ្តល់ឲ្យចាប់ពីដើមរហូតដល់ចុងបញ្ចប់។ អំពើបាបរបស់យើងមិនគ្រាន់តែជាការរំខានដល់ព្រះនោះទេ។ អំពើបាបរបស់មនុស្សជាតិបានផ្តល់លទ្ធផលជាការរងទុក្ខវេទនាយ៉ាងធំក្រៃលែង។ ព្រះមិនទតរំលងកំហឹងរបស់យើង ការរំលោភបំពានដែលយើងបង្កឡើង ការរងទុក្ខវេទនា និងភាពអយុត្តិធម៌ដែលយើងបានព្រងើយកន្តើយនោះទេ។ ព្រះដ៏បរិសុទ្ធ ទ្រង់មិនបែរព្រះនេត្រចេញ ឬបិទព្រះកាណ៌ចំពោះអំពើបាបបែបនេះនោះទេ។ ជនរងគ្រោះដោយសារអំពើបាបស្រែកទាមទារយុត្តិធម៌ ហើយសេចក្តីមេត្តាករុណារបស់ព្រះប្រទានឲ្យនូវអ្វីដែលសេចក្តីសុចរិតរបស់ទ្រង់ត្រូវការ តាមរយៈយញ្ញបូជារបស់ព្រះយេស៊ូវ។

ដោយព្រោះព្រះបុត្រានៃព្រះ គ្មានបាប ការស្ម័គ្រព្រះទ័យរបស់ទ្រង់ក្នុងការរងទុក្ខនៅលើឈើឆ្កាង និងទទួលយកទណ្ឌកម្មដែលយើង សាកសមនឹងទទួល មានតំលៃខ្ពស់ហួសពីការទូទាត់សងណាៗទាំងអស់ដែលមនុស្សជាតិអាចធ្វើទៅទៀត។ សេចក្តីសុចរិតរបស់ព្រះគ្រីស្ទធំអស្ចារ្យជាងសេចក្តីទុច្ចរិតរបស់យើងដូច្នេះហើយបានជាយញ្ញបូជារបស់ទ្រង់គ្រប់គ្រាន់ល្មមនឹងទូទាត់សង សំរាប់សំណងនៃអំពើបាបរបស់លោកិយទាំងមូល នៅគ្រប់ជំនាន់ និងគ្រប់សម័យកាល (រ៉ូម ៥:១៥-១៩ ហេព្រើរ ៩:២៦-២៨, ១ពេត្រុស ៣:១៨, ១យ៉ូហាន ២:២)។ ព្រះបានទទួលយកយញ្ញបូជារបស់ព្រះយេស៊ូវជំនួសឲ្យការដាក់ទណ្ឌកម្មមកលើយើង (១ពេត្រុស ២:២៤)។ ទ្រង់បានសងបំណុលសំរាប់យុត្តិធម៌ដែលយើងមិនអាចសងបាន (ទំនុកដំកើង ៤៧:៧-៩) ទីតុស ២:១១-១៤)។ ការរងទុក្ខរបស់ទ្រង់ធួននឹង (គ្របបាំង) កំហុសរបស់យើង (១យ៉ូហាន ៤:១០)។ ការសុគតរបស់ទ្រង់សង្គ្រោះយើងឲ្យរួចពីស្ថាននរកដែលយើងសាកសមនឹងទទួល (កាឡាទី ៣:១៣-១៤)។

ការផ្គត់ផ្គង់របស់ព្រះគ្រីស្ទ គឺជាដំណឹងល្អដ៏អស្ចារ្យសំរាប់ពួកយើងដែលកំពុងតែតយុទ្ធជាមួយនឹងទោសកំហុសរបស់ខ្លួន។ នៅក្នុងគុកប្អូនប្រុសរបស់ខ្ញុំមិនអាចសងបំណុលសំរាប់បទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្ត ដូចគ្នានឹងយើងដែលមានអំពើបាប មិនអាចសងបំណុលដែលយើងបានជំពាក់ព្រះដ៏បរិសុទ្ធ ដោយព្រោះយើងបានប្រព្រឹត្តល្មើសនឹងច្បាប់របស់ទ្រង់។ ប៉ុន្តែដោយសារតែព្រះយេស៊ូវបានយាងមកសងបំណុលរបស់យើង នោះដាវីឌ អ្នកនិងខ្ញុំអាចរស់នៅដោយគ្មានសេចក្តីខ្មាសនៅក្នុងចិត្ត។

## សេចក្តីសុចរិតរបស់ព្រះគ្រីស្ទ

យញ្ញបូជារបស់ព្រះគ្រីស្ទបំពេញយុត្តិធម៌របស់ព្រះ (រ៉ូម ៣:២០-២៦)។ ខ្ញុំអាចឈរនៅចំពោះព្រះដូចជាមនុស្សម្នាក់ដែលមិនដែលធ្វើបាប (អេសាយ ១:១៨)។ អ្នកទេវសាស្រ្តផ្សេងៗហៅការប្រកាសរបស់ព្រះអំពីឋានៈថ្មីនេះថាជា «ការរាប់ជាសុចរិត»។ ការរាប់ជាសុចរិតគឺជាលទ្ធផលនៃការផ្លាស់ប្តូរដ៏អស្ចារ្យមួយដែលបានកើតឡើងនៅលើឈើឆ្កាងរបស់ព្រះគ្រីស្ទ។ ទ្រង់បានយកអំពើបាបរបស់យើងដាក់នៅលើអង្គទ្រង់ ហើយប្រទានឲ្យយើងនូវសេចក្តីសុចរិតរបស់ទ្រង់ (២កូរិនថូស ៥:២១, ១ពេត្រុស ៣:១៨)។ ទ្រង់បានត្រឡប់ទៅដូចជាយើង (មានបាប) ដើម្បីឲ្យយើងអាចត្រឡប់ទៅដូចជាទ្រង់ (បរិសុទ្ធ)។ ការផ្គត់ផ្គង់ដ៏ធំធេងរបស់ព្រះគ្រីស្ទសំរាប់អំពើបាប ជួយឲ្យខ្ញុំអាចទទួលស្គាល់នូវទំហំនៃអំពើបាបរបស់

ប្អូនប្រុសរបស់ខ្ញុំ ហើយរបស់ខ្ញុំ ហើយនិងរបស់អ្នក។ មិនថាអំពើបាបនៅក្នុងជីវិតរបស់មនុស្សទាំងអស់មានទំហំធំប៉ុណ្ណានោះទេ យញ្ញបូជារបស់ព្រះយេស៊ូវអាចធួនឲ្យបានទាំងអស់។

ភស្តុតាងមួយរបស់ដំណឹងល្អនេះ គឺជាខគម្ពីរដែលត្រូវបានដកស្រង់មកដាក់នៅផ្នែកខាងដើមដំបូងនៃជំពូកនេះ។ សាវ័កប៉ុលសរសេរថា «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកិយដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខមួយក្នុងពួកគេ» (១ធីម៉ូថេ ១:១៥)។ ពេលមុនក្នុងជីវិតរបស់សាវ័កប៉ុល គាត់បានប្រមាថព្រះយេស៊ូវ ហើយថែមទាំងបានសំឡាប់អស់អ្នកដើរតាមទ្រង់ទៀត។ ប៉ុន្តែឥឡូវនេះសាវ័កប៉ុលអាចត្រេកអរ ដោយសារយញ្ញបូជាឲ្យធួនបាបរបស់ព្រះគ្រីស្ទបានសងសំរាប់ទោសកំហុសទាំងនេះបានយ៉ាងពេញលេញ នោះមិនមែនដោយសារតែអំពើបាបរបស់សាវ័កប៉ុលមានទំហំ តូចតាចនោះទេ ប៉ុន្តែដោយសារតែភាពធំធេងនៃឈើឆ្កាងវិញ។ យញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ គ្រប់គ្រាន់ល្មមនឹងធួនឲ្យអំពើបាបដ៏ធំបំផុត និងមនុស្សដែលមានបាបធំបំផុត។

## សេចក្តីស្រលាញ់របស់ព្រះ

ប៉ុន្តែតើយើងទទួលបាននូវអ្វីដែលព្រះគ្រីស្ទប្រទានឲ្យដោយរបៀបណា? ព្រះយេស៊ូវមានបន្ទូលអំពីមនុស្សខ្លះដែលនឹងទៅស្ថាននរក (យ៉ូហាន ៣:១៨ ម៉ាថាយ ២៣:៣៣) ដូច្នេះយើងដឹងថាបើទោះជាយញ្ញបូជាឲ្យធួនបាបរបស់ព្រះគ្រីស្ទ គ្រប់ល្មមសំរាប់មនុស្សគ្រប់គ្នាក៏ដោយ ក៏មិនមែនមនុស្សគ្រប់គ្នាបានទទួលនោះដែរ។ តើយើងមានការធានាអ្វីដែលថាយញ្ញបូជាឲ្យធួនបាបរបស់ព្រះគ្រីស្ទបានប្រទានដល់យើង? ចំលើយគឺថា ព្រះប្រទានអ្វីដែលទ្រង់ត្រូវការ។

ព្រះមិនតំរូវឲ្យយើងទទួលបាននូវការអត់ទោសតាមរយៈអ្វីដែលខ្លួនយើងប្រព្រឹត្តនោះទេ។ ទ្រង់មិនប្រាប់យើងឲ្យបំពេញកាតព្វកិច្ចសំខាន់ខាងព្រលឹងវិញ្ញាណខ្លះ ឬឲ្យមានអារម្មណ៍ស្តាយក្រោយខ្លាំងចំពោះទោសកំហុសរបស់យើង ដើម្បីសងសំរាប់អំពើបាបរបស់យើងនោះទេ។ ផ្ទុយទៅវិញ ដំណឹងល្អនោះគឺថា ព្រះប្រទានការអត់ទោសតាមរយៈព្រះគុណតែមួយមុខគត់ (រ៉ូម ៣:២៣-២៤)។ ទ្រង់ប្រទានសេចក្តីស្រលាញ់របស់ទ្រង់ដល់យើង។ យើងមិនបានទទួលសេចក្តីស្រឡាញ់របស់ទ្រង់តាមរយៈការប្រព្រឹត្តរបស់យើងនោះទេ ។

ប្រសិនបើយើងទទួលបាននូវសេចក្តីស្រឡាញ់របស់ទ្រង់តាមរយៈការប្រព្រឹត្តរបស់យើង នោះវាគឺជារឿងមួយពិបាកខ្លាំងណាស់សំរាប់យើងក្នុងការស្តាប់បង្គាប់តាមបញ្ញត្តិដ៏ធំបំផុតរបស់ទ្រង់ «ត្រូវឲ្យស្រលាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង» (ម៉ាថាយ ២២:៣៧)។ នៅពេល ដែលមនុស្សនិយាយថាពួកគេនឹងស្រលាញ់យើង ប្រសិនបើ យើងបំរើពួកគេ នោះយើងអាចបំរើពួកគេ តែយើងមិនអាចស្រលាញ់ពួកគេបានទេ។ ប្រសិនបើឪពុកម្តាយនិយាយទៅកាន់កូនថា «ម៉ាក់ប៉ានឹងស្រលាញ់កូនបើសិនជាកូន បានពិន្ទុខ្ពស់បំផុតក្នុងមុខវិជ្ជាគណិតវិទ្យា ជួយកាត់ស្មៅ និងឲ្យចំណីឆ្មា។» កូននោះអាចស្តាប់បង្គាប់តាមមែន តែទីបញ្ចប់គាត់នឹងមិនស្រលាញ់មនុស្សដែលមានសេចក្តីស្រលាញ់ ប្រកបដោយឧបាយកលដូច្នេះទេ។

ដូច្នេះហើយបានជាព្រះអម្ចាស់ដែលសព្វព្រះហឫទ័យឲ្យយើងស្រឡាញ់ទ្រង់ បានជួយឲ្យយើងអាចស្រឡាញ់ទ្រង់បានដោយប្រទាននូវសេចក្តីស្រឡាញ់ដល់យើងទុកជាអំណោយដ៏ឥត លក្ខខ័ណ្ឌ។ ព្រះគម្ពីរនិយាយថា «យើងស្រលាញ់ទ្រង់ ដោយព្រោះទ្រង់បានស្រលាញ់យើងជាមុន» (១យ៉ូហាន ៤:១៩)។ ព្រះបើកសំដែងសេចក្តីស្រលាញ់ដែលឥតលក្ខខ័ណ្ឌរបស់ទ្រង់ជាមុន។

## សេចក្តីស្មោះត្រង់របស់ព្រះជាម្ចាស់ចំពោះសម្ព័ន្ធមេត្រី

ព្រះគម្ពីរបង្រៀនយើងច្រើនអំពីសេចក្តីស្រលាញ់ដែលព្រះជាអ្នកចាប់ផ្តើមមុន ដោយកត់ត្រាទុកនូវសម្ព័ន្ធមេត្រីដែលទ្រង់បានបង្កើតជាមួយប្រជារាស្ត្ររបស់ទ្រង់។ តាមរយៈសម្ព័ន្ធមេត្រីបែបនេះ ព្រះសន្យាថានឹងស្រលាញ់ប្រជារាស្ត្ររបស់ទ្រង់ដោយឥតលក្ខខ័ណ្ឌ។ សម្ព័ន្ធមេត្រីទាំងនេះមិនមែនជាកិច្ចសន្យានោះទេ។ កិច្ចសន្យាអាចត្រូវខូចនៅពេលគេមិនធ្វើ

តាមលក្ខខ័ណ្ឌរបស់វា ប៉ុន្តែកង្វះការអនុវត្តន៍តាមមិនលុបនូវសម្ព័ន្ធមេត្រីរបស់ព្រះចោលនោះទេ។ នេះជាមូលហេតុដែលប្រជារាស្ត្ររបស់ព្រះអាចនិយាយថា «បើទុកជាយើងមិនស្មោះត្រង់ក៏ដោយ គង់តែទ្រង់នៅតែស្មោះត្រង់ដដែល» (២ធីម៉ូថេ ២:១៣)។

ការចាកចេញពីទាសភាពរបស់អ៊ីស្រាអែល គឺជាគំរូល្អ មួយនៃសេចក្តីស្រលាញ់ដែលព្រះអង្គសំដែងតាមរយៈសម្ព័ន្ធមេត្រី។ ជាច្រើនសតវត្សមុននេះ ព្រះបានសន្យាថានឹងស្រលាញ់អ័ប្រាហាំ ហើយនិងពូជពង្សរបស់គាត់។ ប៉ុន្តែជាច្រើនដងប្រជារាស្ត្រទាំងនេះបានបរាជ័យក្នុងការស្តាប់តាមទ្រង់។ ពួកគេបានក្លាយជាទាសករក្នុងស្រុកអេស៊ីព្ទរហូតដល់ព្រះបញ្ជូនម៉ូសេទៅរំដោះពួកគេ។ ក្រោយពីរំដោះពួកគេឲ្យរួចពីចំណងទាសភាពហើយ ទើបព្រះប្រទាននូវក្រឹត្យវិន័យដែលនឹងជួយឲ្យពួកអ៊ីស្រាអែលអាចរស់នៅក្នុងជីវិតបរិសុទ្ធបាន។

លំដាប់នៃព្រឹត្តិការណ៍ទាំងនេះមានសារៈសំខាន់សំរាប់ការយល់ដឹងរបស់យើងអំពីសេចក្តីស្រលាញ់ដែលព្រះសំដែងតាមរយៈសម្ព័ន្ធមេត្រី។ ព្រះបានរំដោះប្រជារាស្ត្រមុនពេលទ្រង់បានប្រទានក្រឹត្យវិន័យដល់ពួកគេ។ ទ្រង់មិនបានរង់ចាំឲ្យពួកគេស្តាប់បង្គាប់ទ្រង់មុនពេលទ្រង់សង្គ្រោះពួកគេនោះទេ (សូមមើលចោទិយកថា ៥:៦)។ ទ្រង់មិនបានមានបន្ទូលថា «ចូរស្តាប់បង្គាប់អញ នោះអញនឹងស្រលាញ់ឯង» នោះទេ។ នៅក្នុងសេចក្តីស្មោះត្រង់របស់ទ្រង់ចំពោះសម្ព័ន្ធមេត្រី ទ្រង់បានមានបន្ទូលថា «អញបានស្រលាញ់ឯង បានសង្គ្រោះឯងរួចទៅហើយ ដូច្នេះឯងគួរតែដើរតាមក្រឹត្យវិន័យទាំងនេះដែលនឹងធ្វើឲ្យជីវិតរបស់ឯងបានពរ»។

ព្រះគុណរបស់ព្រះចំពោះយើងដែលសំដែងឲ្យឃើញតាមរយៈការដែល ទ្រង់ស្រលាញ់យើងទាំងមុនយើងបានស្រលាញ់ ឬស្តាប់បង្គាប់ទ្រង់ គឺជាផ្នែកមួយដ៏សំខាន់នៃដំណឹងល្អ (រ៉ូម ៥:៨)។ ប្រសិនបើព្រះរង់ចាំឲ្យយើងរស់នៅបានត្រឹមត្រូវសិន មុននឹងទ្រង់ស្រលាញ់យើង នោះនឹងគ្មានសង្ឃឹមទាល់សោះសំរាប់មនុស្សដូចជាប្អូនប្រុសរបស់ខ្ញុំដែលកំពុងតែជាប់គុកនោះ។ ជីវិតរបស់ដាវីឌពេញទៅដោយបញ្ហាច្របូកច្របល់ គ្មានផ្លូវដែលគាត់អាចកែទោសកំហុសដែលគាត់បានធ្វើនោះទេ។ គាត់គ្មានទាំងសេរីភាពខាងឯរូបកាយ និង សមត្ថភាពខាងផ្លូវសតិបញ្ញាដើម្បីធ្វើឲ្យការខូចខាតដែលគាត់បានធ្វើចំពោះអ្នកដទៃអាចត្រឡប់ទៅកាន់សភាពដើមវិញបានឡើយ។ ប៉ុន្តែនៅពេលគាត់បានទទួលស្គាល់សេចក្តីពិតដែលថាព្រះយេស៊ូវស្រលាញ់គាត់ ហើយនឹងជួយគាត់ នោះដាវីឌបានទទួលព្រះគុណរបស់ព្រះ បើទោះជាគាត់បានធ្វើបាបអស់រយៈពេលជាច្រើនឆ្នាំ ហើយនិងអសមត្ថភាពខាងផ្លូវសតិបញ្ញាអស់មួយជីវិតក៏ដោយ។

ក្នុងជីវិតជាមនុស្សពេញវ័យ ដាវីឌបាននិយាយមកកាន់គ្រួសាររបស់គាត់ដោយប្រើប្រយោគសមញ្ញាដូចជាកូនក្មេងទើបរៀនចេះនិយាយយ៉ាងដូច្នេះ (ពីព្រោះគាត់អសមត្ថភាពខាងសតិបញ្ញា) និងពូកែគ្រហឹម។ ប៉ុន្តែនៅពេលគាត់បានទុកចិត្តលើសេចក្តីស្រលាញ់របស់ព្រះយេស៊ូវសំរាប់គាត់ នោះដាវីឌបានចាប់ផ្តើមផ្ញើរសំបុត្រមកកាន់ពួកយើង។ យើងមិនដែលដឹងសោះថាគាត់ចេះសរសេរ។ ការប្រកបពាក្យ និងវេយ្យាករណ៍មានលក្ខណៈដូចកូនក្មេង ប៉ុន្តែជំនាញនៃការសរសេរក៏ដូចជាសមត្ថភាពរបស់ដាវីឌក្នុងការបរិយាយអំពីសេចក្តីជំនឿរបស់គាត់មានលក្ខណៈល្អប្រសើរឡើងជាលំដាប់។ គាត់បានសរសេរពីក្នុងគុកមកថា «ព្រះអាចធ្វើការអស្ចារ្យសំរាប់មនុស្សគ្រប់គ្នាដែលជឿដល់ទ្រង់។ ខ្ញុំជឿដល់ទ្រង់។ ទ្រង់បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ព្រះនាមយេស៊ូវមកសុគតជំនួសអំពើបាបរបស់យើង។ ព្រះស្រលាញ់លោកិយនេះខ្លាំងដ៏ម្ល៉េះបានជាទ្រង់បានប្រទានព្រះរាជបុត្រាទ្រង់តែមួយ។ អស់អ្នកណាដែលជឿដល់ទ្រង់នឹងមិនត្រូវវិនាសឡើយ គឺមានជីវិតអស់កល្បជានិច្ចវិញ»។

តាមរយៈការរៀបពាក្យនៅក្នុងយ៉ូហាន ៣:១៦ ដោយខ្លួនឯង ដាវីឌបានប្រាប់គ្រប់គ្នាដែលគាត់ស្គាល់នូវដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ៖ ដំណឹងល្អនេះធំល្មមសំរាប់លោកិយទាំងមូល វាធំល្មមសំរាប់អំពើបាបទាំងអស់របស់យើង ហើយអស់អ្នកដែលជឿដល់ទ្រង់អាចទទួលនូវដំណឹងល្អនេះបាន។

## សេចក្ដីជំនឿលើព្រះគ្រីស្ទ

អស់អ្នកដែលជឿលើព្រះយេស៊ូវនោះបានទទួលសេចក្ដីសន្យានៅក្នុងដំណឹងល្អ។ ព្រះមិនមានបន្ទូលថា ទ្រង់នឹងសង្គ្រោះអស់អ្នកដែលឡើងភ្នំ ឬបញ្ឈប់ការញៀនថ្នាំ ឬកាត់បន្ថយភាពក្រីក្រ ឬសាងអំពើល្អ ឲ្យបានដល់កំរិតណាមួយនោះទេ។ ទ្រង់សង្គ្រោះអស់អ្នកណាដែលគ្រាន់តែជឿលើព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់ពួកគេប៉ុណ្ណោះ (យ៉ូហាន ៣:១៦)។

ស្ថានភាពរបស់ដាវីឌប្អូនប្រុសរបស់ខ្ញុំជួយយើងឲ្យយល់អំពីសេចក្ដីជំនឿ។ យើងមិនគួរគិតថា សេចក្ដីជំនឿលើព្រះយេស៊ូវកើតឡើងពីការល្អដែលយើងប្រព្រឹត្ត ដែលធ្វើឲ្យទ្រង់ស្រលាញ់យើងនោះទេ។ យោងតាមគំនិតនេះ យើងប្រាកដជាគិតថាសេចក្ដីជំនឿធ្វើឲ្យយើងប្រសើរជាងអ្នកដទៃទៀតបន្តិចដែរ។ ប៉ុន្តែបើយើងមានទស្សនៈអំពីសេចក្ដីជំនឿបែបនេះ នោះខុសធំហើយ។ តើការធ្វើល្អតែបន្តិចបន្តួចដូចជាការទទួលស្គាល់ថាការសុគតរបស់ព្រះយេស៊ូវសំរាប់អំពើបាបអាចទូទាត់សងសំរាប់ឃាតកម្ម និងការប្រមាថព្រះរបស់សាវ័កប៉ុលបានយ៉ាងដូចម្ដេច? តើសេចក្ដីជំនឿរបស់ប្អូនប្រុសរបស់ខ្ញុំលើយញ្ញបូជារបស់ព្រះគ្រីស្ទអាចទូទាត់សងសំរាប់បទឧក្រិដ្ឋ ដែលគាត់បានធ្វើកន្លងមកយ៉ាងដូចម្ដេច? ប្រសិនបើព្រះបានមានបន្ទូលថា សេចក្ដីជំនឿរបស់យើង គឺជាអំពើល្អរបស់យើង។ វា មានតំលៃស្មើនឹងអំពើអាក្រក់របស់យើង ដូច្នេះវាអាចសង្គ្រោះយើងបាន នោះមានន័យថាទ្រង់មិនសុចរិតទេ។ យើងត្រូវតែយល់ថាគឺជាយញ្ញបូជារបស់ព្រះគ្រីស្ទទេ មិនមែនជាសេចក្ដីជំនឿរបស់យើងទេ ដែលជាអំពើសុចរិតដែលមានតុល្យភាពនឹងជញ្ជីងយុត្តិធម៌របស់ព្រះ។

ប្រសិនបើព្រះជាម្ចាស់ប្រទានព្រះគុណដល់យើងដោយព្រោះសេចក្ដីជំនឿរបស់យើងនោះបានសេចក្ដីថាយើងជាអ្នកទទួលខុសត្រូវចំពោះសេចក្ដីសង្គ្រោះរបស់ខ្លួនឯង។ យើងនឹងសរសើរខ្លួនឯង។ ប៉ុន្តែព្រះគម្ពីរនិយាយច្បាស់ថា ព្រះយេស៊ូវសង្គ្រោះ។ សេចក្ដីជំនឿរបស់យើងមិនធ្វើឲ្យយើងសមនឹងទទួលសេចក្ដីស្រលាញ់ ឬព្រះគុណរបស់ទ្រង់នោះទេ។ ឧបមាតាមានមនុស្សម្នាក់ដែលត្រូវបានគេសង្គ្រោះឲ្យរួចពីការលង់ទឹក ហើយអ្នកនោះដើរតាមឆ្នេរសមុទ្រហើយតាំងស្រែកអួតថា «ខ្ញុំនៅរស់ទេពីព្រោះខ្ញុំជាមនុស្សឆ្លាត។ ខ្ញុំស្រែកហៅឲ្យមានអ្នកមកជួយសង្គ្រោះខ្ញុំទាន់»។ គ្រប់គ្នាដឹងថាអ្នកនោះដែលគេជួយសង្គ្រោះគ្មានហេតុផលដើម្បីអួតនោះទេ។ សេចក្ដីសង្គ្រោះរបស់គាត់ គឺពិតជាលទ្ធផលដែលកើតឡើងពីការពឹងផ្អែកលើសេចក្ដីល្អ និងសមត្ថភាពរបស់អ្នក ដែលបានជួយសង្គហគ្រោះគាត់ទាំងស្រុង។

ការពឹងផ្អែកទាំងស្រុងលើអ្នកដទៃ គឺជារឿងមួយផ្ទុយស្រឡះពីការយល់ច្រឡំទីពីរ អំពីសេចក្ដីជំនឿដែលសង្គ្រោះ ដែលថាប្រសិទ្ធិភាពនៃសេចក្ដីជំនឿរបស់យើង គឺពឹងផ្អែកលើកំលាំងនៃសេចក្ដីជំនឿរបស់យើង។ មនុស្សគិតថាតាមរយៈការខិតខំខ្លាំង ឬការសិក្សាខាងផ្នែកទេវសាស្ត្រ នោះពួកគេនឹងមានសេចក្ដីជំនឿល្អមនៅក្នុងចិត្តដើម្បីធ្វើព្រះស្រលាញ់ពួកគេ ឬធ្វើឲ្យខ្លួនពួកគេសមនឹងទទួលសេចក្ដីស្រលាញ់របស់ព្រះ។ ប៉ុន្តែគំនិតដែលថាសេចក្ដីសង្គ្រោះពឹងផ្អែកលើសេចក្ដីជំនឿខ្លាំងរបស់យើង គឺគ្រាន់តែជារបៀបមួយធ្វើឲ្យសេចក្ដីជំនឿក្លាយជាការងារមួយដែលយើងត្រូវការធ្វើដើម្បីឲ្យបានប្រសើរជាងអ្នកដទៃទៀតតែប៉ុណ្ណោះ។ ការនេះដូចគ្នានឹងអ្នកហែលទឹកដែលអួតនៅលើឆ្នេរសមុទ្រថា «ខ្ញុំបានសង្គ្រោះហើយ ពីព្រោះខ្ញុំបានតោងអ្នកដែលបានជួយសង្គ្រោះខ្ញុំជាប់ដោយប្រើកំលាំងខ្លាំងជាងអ្នកដទៃទៀត»។

ដើម្បីយល់អំពីសេចក្ដីជំនឿស្របតាមព្រះគម្ពីរ យើងត្រូវតែគិតអំពីខ្លួនរបស់យើងថាបានខ្សោះខ្សោយកំលាំងទាំងស្រុងដោយព្រោះបានព្យាយាមរក្សាព្រលឹងវិញ្ញាណរបស់ខ្លួនឲ្យរស់ ហើយបែរមកពឹងផ្អែកទាំងស្រុងលើកំលាំងរបស់ព្រះយេស៊ូវដើម្បីសង្គ្រោះយើងវិញ។ សេចក្ដីសង្ឃឹមរបស់យើងមិនអាចផ្អែកលើកំលាំងនៃសេចក្ដីជំនឿរបស់យើងបានទេ រលកនៃភាពកម្សោយ និងការសង្ស័យមានកំលាំងខ្លាំងលើសជាងកំលាំងនៃសេចក្ដីជំនឿរបស់យើងទៅទៀត។ សេចក្ដីសង្ឃឹមរបស់យើង គឺផ្អែកលើការផ្គត់ផ្គង់របស់ព្រះយេស៊ូវតែមួយមុខប៉ុណ្ណោះ។

ពេលស្រមៃឃើញប្អូនប្រុសរបស់ខ្ញុំភ័យញ័រខ្លួនចំប្រប់នៅក្នុងគុក ទាំងអសមត្ថភាពខាងសតិបញ្ញា មានអារម្មណ៍នឿយហត់ និងជាប់ពិរុទ្ធដ៏ធំ ខ្ញុំពិតជាមិនចង់ឲ្យកំលាំងនៃសេចក្ដីជំនឿរបស់ប្អូនប្រុសរបស់ខ្ញុំ ក្លាយទៅជាមូលដ្ឋានគ្រឹះនៃសេចក្ដី

សង្ឃឹមរបស់គាត់នោះទេ ។ ខ្ញុំចង់ឲ្យសេចក្ដីសង្ឃឹមរបស់គាត់មានមូលដ្ឋានគ្រឹះស្ថិតនៅ លើកំលាំងនៃសេចក្ដីស្រលាញ់របស់ព្រះយេស៊ូវវិញ។ សេចក្ដីសង្ឃឹមរបស់គាត់ត្រូវតែដូចគ្នានឹងសេចក្ដីសង្ឃឹមរបស់សាវ័កប៉ុលដែលគាត់បានយល់ថាគាត់មិនអាចពឹងផ្អែកលើប្រាជ្ញា ភាពឆេះឆួល និងកំលាំងរបស់ខ្លួនឯង ធ្វើជាមូលដ្ឋានសំរាប់សេចក្ដីសង្គ្រោះរបស់ព្រះបានឡើយ។ សាវ័កប៉ុលបានសរសេរថា «ត្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន» (អេភេសូរ ២:៨-៩)។

សេចក្ដីជំនឿមិនមែនជាការប្រព្រឹត្ត ឬបទពិសោធន៍ខាងអារម្មណ៍នោះទេ។ យើងមិនអាចអួតថាយើងមានសេចក្ដីជំនឿគ្រប់គ្រាន់ដើម្បីទទួលបានសេចក្ដីស្រលាញ់របស់ព្រះបានទេ។ សេចក្ដីជំនឿដែលសង្គ្រោះ ទទួលស្គាល់ថា គ្មានអ្វីនៅក្នុងយើងដែលអាចធ្វើឲ្យព្រះស្រលាញ់យើងនោះឡើយ។ យើងពឹងផ្អែកលើព្រះយេស៊ូវតែមួយក្នុងការសង្គ្រោះយើងចេញពីអំពើបាបរបស់យើង។ យើងមិនជឿថា អ្វីដែលយើងធ្វើ គ្រប់គ្រាន់ក្នុងការធ្វើឲ្យព្រះស្រលាញ់យើងទេ គឺមិនមែនជាការប្រព្រឹត្តរបស់យើងទេ មិនមែនជាគំនិតវៃឆ្លាតរបស់យើងទេ ក៏មិនមែនជាកំលាំងនៃសេចក្ដីជំនឿរបស់យើងដែរ។ យើងទុកចិត្តថា ព្រះយេស៊ូវសង្គ្រោះ។

ព្រះប្រើអស់ទាំង សេចក្ដីអស់សង្ឃឹម និងការធ្លាក់ទឹកចិត្តរបស់យើងដើម្បីនាំយើងមកពឹងផ្អែកទាំងស្រុងលើទ្រង់ តាមរយៈការបដិសេធមិនឲ្យសេចក្ដីល្អរបស់យើងធ្វើជាមូលដ្ឋានគ្រឹះនៃការឯកភាពរបស់ព្រះ ហើយដាក់សេចក្ដីជំនឿរបស់យើងនៅក្នុងព្រះគ្រីស្ទវិញ។ នៅពេលយើងមិនមានអ្វីផ្សេងទៀតធ្វើជាមូលដ្ឋានគ្រឹះនៃសេចក្ដីសង្ឃឹមប៉ុន្តែមានតែព្រះយេស៊ូវប៉ុណ្ណោះ នោះយើងនឹងងាកចេញពីអ្វីៗទាំងអស់ត្រឡប់មកឯទ្រង់វិញ។ នេះជាហេតុផលមួយដែលជំរុញឲ្យសាវ័កប៉ុលនិយាយថា សូម្បីតែសេចក្ដី ជំនឿដែលយើងមានក៏ជាអំណោយទានរបស់ព្រះដែរ (អេភេសូរ ២:៨-៩)។ សេចក្ដីជំនឿដែលសង្គ្រោះមិនអាចជាអ្វីដែលយើងបង្កើត ដោយការខិតខំប្រឹងប្រែងរបស់យើងនោះឡើយ។ ប្រសិនបើព្រះមិនបានផ្លាស់ប្តូរចិត្តរបស់យើងសំរាប់ទ្រង់នោះទេ នោះយើងនឹងស្លាប់ខាងព្រលឹងវិញ្ញាណទៅហើយ (អេសេគាល ៣៦:២៦ អេភេសូរ ២:១)។

## សេចក្ដីសំរាកក្នុងព្រះគ្រីស្ទ

សេចក្ដីជំនឿស្របតាមព្រះគម្ពីរ មានន័យថា មិនទុកចិត្តលើទំហំនៃចំណេះដឹងដែលយើងមាន សេចក្ដីក្លៀវក្លារបស់យើង ឬការបន្ទោសខ្លួនឯងរបស់យើងនោះទេ ប៉ុន្តែពឹងផ្អែកលើការងាររបស់ព្រះគ្រីស្ទវិញ។ យើងមិនពឹងលើកំលាំងនៃសេចក្ដីជំនឿរបស់យើងដើម្បីឲ្យយើងនៅជាប់នឹងទ្រង់នោះទេ ប៉ុន្តែពឹងលើកំលាំងនៃសេចក្ដីស្រលាញ់របស់ទ្រង់ដើម្បីលើកយើងទៅឯទ្រង់វិញ។ ដូចជាមនុស្សខ្វាំងម្នាក់ដែលចូលទៅក្នុងជណ្តើរយន្តមិនពឹងលើសាច់ដុំរបស់គាត់ទេ តែពឹងលើខ្សែកាបពីលើដើម្បីលើកគាត់ឡើងវិញ ដូច្នេះសេចក្ដីជំនឿស្របតាមព្រះគម្ពីរក៏ដូច្នេះដែរ គឺមិនមែនជាការខិតខំរបស់យើងដើម្បីស្រលាញ់ព្រះនោះទេ តែយើងបង្ហាញការពឹងផ្អែករបស់យើងលើព្រះវិញ។ យើងមិនពឹងផ្អែកលើសេចក្ដីជំនឿរបស់យើងលើព្រះយេស៊ូវខ្លាំង ឲ្យដូចដែល យើងសំរាកក្នុងសេចក្ដីស្រលាញ់ដ៏អស្ចារ្យរបស់ទ្រង់សំរាប់យើងនោះទេ (អេសាយ ៣០:១៥ ហេព្រើរ ៤:៩-១១)។ យើងទុកចិត្តលើសេចក្ដីមេត្តាករុណាដែលទៀងទាត់ និងមិនចេះប្រែប្រួលរបស់ព្រះដែលប្រកបដោយឫទ្ធានុភាពជាជាងលើការខិតខំប្រឹងប្រែងដ៏ស្ពួចស្តើងរបស់យើង

នៅពេលយើងបើកចិត្តរបស់យើងចំពោះសេចក្ដីស្រលាញ់ដែលឥតលក្ខខ័ណ្ឌរបស់ព្រះ នោះយើងរកឃើញសន្តិភាពដែលគួរឲ្យភ្ញាក់ផ្អើល និង ផ្អែមល្ហែម (រ៉ូម ៥:១-២)។ យើងដឹងថា ព្រះបានទទួលយកយើង ដូច្នេះយើងមិនចាំបាច់បារម្ភអំពីការបំពេញព្រះទ័យព្រះ ឬលួងលោមឲ្យទ្រង់រំងាប់សេចក្ដីក្រោធរបស់ទ្រង់ចំពោះយើង (អេភេសូរ ២: ១៧-១៩)។ យើងក៏ដឹងដែរថា ការទុកចិត្តលើព្រះយេស៊ូវនោះ គឺមិនមែនមានន័យថាយើងត្រូវរស់នៅក្នុងការភ័យខ្លាចជារៀងរាល់ថ្ងៃដោយគិតថាព្រះទ្រង់កំពុងតែជ្រួញចិញ្ចើមដាក់យើងនោះទេ។ ដោយព្រោះសេចក្ដីជំនឿរបស់យើងនៅលើការងារដែលព្រះគ្រីស្ទបាន

ធ្វើដើម្បីសង្គ្រោះយើងតែមួយគត់ នោះជីវិតគ្រីស្ទបរិស័ទ គឺមិនមែនជាការខិតខំដោយនឿយហត់ដើម្បីឲ្យព្រះអង្គ ទទួលយើងនោះទេ។ យើងសំរាកនៅក្នុងព្រះគុណដែលគ្របបាំងអំពើបាបរបស់យើង ឈ្នះលើភាពបរាជ័យរបស់យើង ហើយផ្តល់ឲ្យយើងនូវសេចក្តីសុចរិតរបស់ព្រះយេស៊ូវ។

យើងលែងតស៊ូដើម្បីធ្វើឲ្យព្រះស្រលាញ់យើងទៀតហើយ។ ទ្រង់ស្រលាញ់យើង! ហើយប្រសិនបើស្តេចនៃស្ថានសួគ៌ញញឹមដាក់យើង នោះយើងមិនគួរអស់សង្ឃឹមដោយសារស្មាព្រះហស្តខ្លះរបស់ទ្រង់មិនស្រលាញ់យើង ឬថាស្ថានភាពរបស់យើងហាក់ដូចជា អស់សង្ឃឹមនោះទេ។ មិនថាអំពើបាបរបស់យើងមានទំហំធំធេង ឬធម្មតា មិនថាយើងជឿថាជីវិតរបស់យើងឥតខ្លឹមសារ ឬពេញលេញពេក មិនថាយើងរស់នៅក្នុងផ្ទះស្អាត ឬក្នុងគុក ព្រះគុណរបស់ព្រះធ្វើឲ្យយើងត្រឡប់ជាសុចរិតដូចជាព្រះយេស៊ូវនៅចំពោះព្រះភ័ក្ត្ររបស់ព្រះ ទ្រង់ស្រលាញ់យើងដូចជាទ្រង់ស្រលាញ់ព្រះយេស៊ូវដែរ។ សំរាប់អស់អ្នកណាដែលបានសោក សៅចំពោះកំហុសរបស់ខ្លួន ស្តាយក្រោយចំពោះភាពបរាជ័យរបស់ខ្លួន ហើយភ័យខ្លាចចំពោះអនាគតរបស់ខ្លួន សេចក្តីស្រលាញ់នេះ គឺជាសេចក្តីកំសាន្តចិត្តដ៏អស្ចារ្យដែលពួកគេអាចនឹងសំរាក បាន។ ប៉ុន្តែនៅតែមានដំណឹងល្អច្រើនទៀតនៅក្នុងដំណឹងល្អ។

## *ព្រះធ្វើឲ្យអ្វីដែលទ្រង់ផ្តត់ផ្គង់បានត្រឡប់ជាឥតខ្ចោះ៣*

ការបានរាប់ជាសុចរិតដោយព្រះគុណគឺជាការអស្ចារ្យ ប៉ុន្តែផែនការរបស់ព្រះមានច្រើនជាងនេះទៅទៀត។ ព្រះយេស៊ូវគ្រីស្ទមិនគ្រាន់តែសង្គ្រោះយើងចេញពីអំពើបាបកន្លងមកនោះទេ ប៉ុន្តែក៏ធានាជីវិតអស់កល្បជានិច្ចរបស់យើងជាមួយទ្រង់ផងដែរ។ នេះជាមូលហេតុដែលព្រះយេស៊ូវបានមានបន្ទូលថា អស់អ្នកណាដែលជឿដល់ទ្រង់ «មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦)។ សេចក្តីសង្គ្រោះរបស់ព្រះមិនមែនដូចជាការដែលត្រូវបានសង្គ្រោះពីឲ្យរួចពីក្រញ៉ាំសត្វខ្លាថ្ងៃមួយ ហើយបន្ទាប់មកត្រូវបានបោះចូលទៅក្នុងព្រៃនៅថ្ងៃបន្ទាប់នោះទេ។ ដំណឹងល្អរួមបញ្ចូលទាំងរបៀបដែលព្រះថែរក្សាយើងឲ្យមានសុវត្ថិភាពខាងព្រលឹងវិញ្ញាណអស់កល្បជានិច្ច។

### ការរួបរួមជាមួយព្រះយេស៊ូវ

ព្រះមិនត្រឹមតែស្រលាញ់យើងខ្លាំងដូចជាទ្រង់ស្រលាញ់ព្រះយេស៊ូវនោះទេ ប៉ុន្តែព្រះគុណរបស់ព្រះក៏ធ្វើឲ្យយើងត្រឡប់ជាកូនរបស់ទ្រង់ផងដែរ។ សាវ័កយ៉ូហានសរសេរថា «មើល សេចក្តីស្រលាញ់យ៉ាងណាហ្ន៎ ដែលព្រះវរបិតាបានផ្តល់មកយើងរាល់គ្នា ឲ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ (១យ៉ូហាន ៣:១)។ ប៉ុន្តែតើធ្វើយ៉ាងម៉េចឲ្យយើងក្លាយជាកូនរបស់ព្រះបាន បើយើងបានកើតតាមរយៈឪពុកម្តាយដែលជាមនុស្សនោះ? យើងត្រូវបានទទួលជាកូនចិញ្ចឹមដោយព្រះវរបិតានៃស្ថានសួគ៌ (អេភេសូរ ១:៥-៦)។ តើព្រះទទួលយើងជាកូនចិញ្ចឹមដោយរបៀបណា? យើងបានបរិយាយអំពីរបៀបដែលព្រះទទួលយើងជាកូនចិញ្ចឹមរួចហើយ៖ គឺយើងពឹងផ្អែកលើព្រះគ្រីស្ទសំរាប់ជីវិតខាងព្រលឹងវិញ្ញាណរបស់យើងជាមួយព្រះ។ យើងធ្វើការនេះដោយសារភាពថាយើងត្រូវការព្រះយេស៊ូវដើម្បីធ្វើឲ្យយើងបានបរិសុទ្ធ ទទួលស្គាល់អំពើបាបរបស់យើង និងកង្វះនូវគំនិត ពាក្យសំដី និងទង្វើរបស់យើង ដើម្បីឲ្យយើងបានផ្សះផ្សាជាមួយព្រះវិញ។ បន្ទាប់មកព្រះរាប់យើងជាសុចរិតដោយព្រះគុណរបស់ទ្រង់តែមួយគត់ ហើយព្រះរាប់យើងជាសុចរិត និងស្រលាញ់យើងដូចជាព្រះយេស៊ូវដែរ។

ប្រសិនបើការតស៊ូទាំងអស់របស់យើងមិនផ្តល់កំណើតដល់ជីវិតខាងព្រលឹងវិញ្ញាណជាមួយព្រះទេ នោះបានសេចក្តីថា យើងគ្មានសេចក្តីសង្ឃឹមសោះចំពោះការប្រព្រឹត្តរបស់យើងទេ គឺយើងបានស្លាប់ហើយ។ ដំណឹងល្អប្រកាសថា ការសន្និដ្ឋានបែបនេះ គឺពិតជាត្រឹមត្រូវណាស់។ ហើយតាមពិតទៅសេចក្តីស្លាប់នេះ គឺជាទ្វារចូលទៅជីវិតថ្មីនៅក្នុងក្រុមគ្រួសារនៃព្រះ។

*របួមជាមួយការសុគតរបស់ព្រះគ្រីស្ទ*។ បន្ទាប់ពីសាវ័កប៉ុលថ្លែងថា ការធ្វើល្អមិនអាចរាប់មនុស្សម្នាក់ជាសុចរិតនៅចំពោះព្រះដ៏បរិសុទ្ធបានទេ សាវ័កប៉ុលបន្ថែមទៀតថា «ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែខ្ញុំរស់នៅមិនមែនជាខ្ញុំ

ទៀត» (កាឡាទី ២:២០)។ ពាក្យទាំងនេះជាការសន្និដ្ឋានជាក់ស្តែងដែលថា ការឈរនៅចំពោះព្រះមានមូលដ្ឋានគ្រឹះស្ថិតនៅ លើយញ្ញបូជារបស់ព្រះយេស៊ូវ ហើយមិនស្ថិតនៅលើសេចក្តីល្អរបស់យើងទេ។ សេចក្តីសង្ឃឹមរបស់យើង គឺនៅក្នុងអ្វីដែលទ្រង់បានធ្វើ ជាជាង អ្វីដែលយើងបានធ្វើ។ អត្តសញ្ញាណរបស់យើងត្រូវបានត្បាញបញ្ចូលគ្នាជាមួយនិងអត្តសញ្ញាណរបស់ព្រះគ្រីស្ទ។

ស្តាប់ទៅហាក់បីដូចជាអាក្រក់មែនទែនដែលត្រូវរួបរួមជាមួយការសុគតរបស់ព្រះគ្រីស្ទ ប៉ុន្តែវាជាការល្អវិញ។ បើសិនសេចក្តីពិតទាំងអស់អំពីយើងត្រូវបានវាយភ្ជាប់ទៅនឹងឈើឆ្កាង នោះមានន័យថា អំពើបាប គុណវិបត្តិ និងភាពបរាជ័យទាំងអស់របស់យើងគឺនៅលើឈើឆ្កាងនោះផងដែរ។ ដោយព្រោះគ្រប់យ៉ាងដែលអាចបំបែកយើងខាងព្រលឹងវិញ្ញាណចេញពីព្រះជាប់នៅលើឈើឆ្កាង នោះទ្រង់អាចទាញយើង មកជិតអង្គទ្រង់បាន។ ប៉ុន្តែតើទំនាក់ទំនងនេះជាមួយព្រះមានប្រយោជន៍ទេ បើសិនជាយើងបានស្លាប់ខាងព្រលឹងវិញ្ញាណទៅហើយ? សាវ័កប៉ុលឆ្លើយដោយរំលឹកយើងថា ឥឡូវនេះជីវិតខាងព្រលឹងវិញ្ញាណរបស់យើង អត្តសញ្ញាណរបស់យើងនៅចំពោះព្រះ មានកំណើតចេញមកពីប្រភពមួយផ្សេងទៀត។

*រួបរួមជាមួយជីវិតរបស់ព្រះគ្រីស្ទ*។ យើងមិនត្រឹមតែរួបរួមជាមួយការសុគតរបស់ព្រះគ្រីស្ទប៉ុណ្ណោះទេ តែយើងក៏រួបរួមជាមួយជីវិតរបស់ព្រះគ្រីស្ទផងដែរ។ សាវ័កប៉ុលសរសេរថា «ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែខ្ញុំរស់នៅមិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ» (កាឡាទី ២:២០)។ ពាក្យទាំងនេះមិនត្រឹមតែធានាយើងអំពីជីវិតថ្មីជាមួយព្រះគ្រីស្ទនោះទេ ប៉ុន្តែក៏ទាក់ទងនឹងចំនុចសំខាន់នៃដំណឹងល្អដែលយើងបានលើកឡើងខ្លះៗកន្លងមក ដែលនោះគឺជាការរស់ឡើងវិញ។

នៅពេលព្រះយេស៊ូវបានរងទុក្ខនៅលើឈើឆ្កាងសំរាប់អំពើបាបរបស់យើង ទ្រង់ក៏បានលុបចោលទណ្ឌកម្មដែលកើតឡើង នៅពេលមនុស្សដំបូងបានបោះបង់ចោលផ្លូវរបស់ព្រះ។ ព្រះបានប្រាប់អ័ដាមថា ប្រសិនបើគាត់មិនស្តាប់បង្គាប់ នោះអ័ដាមនឹងត្រូវស្លាប់ជាពិត (លោកុប្បត្តិ ២:១៧)។ អំពើបាបរបស់អ័ដាមបានបំបែកចំណងដ៏ជិតស្និទ្ធនៃជីវិតរវាងព្រះដ៏បរិសុទ្ធ និងចិត្តរបស់មនុស្សជាតិ។ ព្រះបានឆ្លើយតបដោយប្រោសឲ្យព្រះយេស៊ូវបានរស់ពីការសុគតឡើងវិញដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធដើម្បីបង្ហាញថាលទ្ធផលនៃអំពើបាបដើមដំបូងនេះពិតជាអាចលុបចោលដោយយញ្ញបូជារបស់ព្រះគ្រីស្ទ (រ៉ូម ៨:១១, ១កូរិនថូស ១៥:១៥-២០)។

ជីវិតរបស់ព្រះយេស៊ូវបន្ទាប់ពីការសុគតបង្ហាញថា សេចក្តីសន្យារបស់ព្រះអំពីការលុបចោលនូវអំពើបាប និងការប្រទាននូវជីវិតអស់កល្ប គឺជាការពិតសំរាប់យើង។ អំពើបាបរបស់យើងមិនបញ្ចប់នូវទំនាក់ទំនងរបស់យើងជាមួយព្រះនោះទេ ហើយចុងបញ្ចប់នៃជីវិតរបស់យើងនៅលើផែនដីក៏មិនបញ្ចប់នូវទំនាក់ទំនងរបស់យើងជាមួយព្រះដែរ។ នៅពេលយើងស្លាប់ខាងសាច់ឈាម វិញ្ញាណរបស់យើងនឹងបន្តរួមប្រកបជាមួយនឹងព្រះអម្ចាស់អស់កល្បជានិច្ច។ ក៏នឹងមានពេលមួយមកដល់ដែលព្រះនឹងប្រោសរូបកាយរបស់យើងឲ្យរស់ឡើងវិញ ដូចជាទ្រង់បានប្រោសព្រះយេស៊ូវដែរ ដើម្បីឲ្យយើងបានរួបរួមនៅក្នុងរូបកាយ និងវិញ្ញាណជាមួយព្រះយេស៊ូវ។ បន្តិចទៀតយើងនឹងពន្យល់អំពីផ្នែកនេះនៃដំណឹងល្អ។

ជាការសំខាន់ដែលដឹងថា ការដែលវិញ្ញាណរបស់អ្នកជឿទាំងអស់រួបរួមជាមួយនឹងព្រះគ្រីស្ទ គឺជាលទ្ធផលនៃការរស់ឡើងវិញរបស់ព្រះយេស៊ូវ។ ទោះបើព្រះគ្រីស្ទទ្រង់សុគត ទ្រង់បានមានព្រះជន្មរស់ឡើងវិញម្តងទៀត ហើយទ្រង់រស់នៅក្នុងយើង នៅក្នុងការរួបរួមខាងវិញ្ញាណជាមួយវិញ្ញាណរបស់យើង។ ចូរចងចាំថាសាវ័កប៉ុលបាននិយាយថា «ព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំ»។ ប្រសិនបើយើងស្លាប់ (ដោយព្រោះគ្មានអ្វីដែលខំធ្វើជួយឲ្យព្រះទទួលយកយើងបាន) ហើយព្រះយេស៊ូវរស់នៅក្នុងយើង (ដោយព្រោះវិញ្ញាណរបស់ទ្រង់បានរួបរួមជាមួយនឹងវិញ្ញាណរបស់យើង) នោះយើងមានអត្តសញ្ញាណរបស់ព្រះយេស៊ូវហើយ។ អ្វីទាំងអស់ដែលជាលក្ខណៈសម្បត្តិរបស់ព្រះយេស៊ូវ (ប្រាជ្ញា ភាពបរិសុទ្ធ និងសេចក្តីសុចរិតរបស់ទ្រង់) បានចូលមកជំនួសសេចក្តីចំកួត អំពើបាប និងការបះបោររបស់យើង (១កូរិនថូស ១:៣១)។ សាវ័កប៉ុលមាន

អំណរដែលព្រះគ្រីស្ទ គឺជាជីវិតរបស់យើង (កូល៉ុស ៣:៤) ហើយ «ដែលខ្ញុំរស់នៅ នោះគឺសំរាប់ព្រះគ្រីស្ទ» (ភីលីព ១:២១)។ តាមរយៈការរួបរួមខាងវិញ្ញាណរបស់យើងជាមួយនឹងព្រះគ្រីស្ទ នោះគ្រប់ទាំងអស់ដែលធ្វើឲ្យយើងមានសេចក្តីខ្មាសបានស្លាប់ ហើយគ្រប់ទាំងអស់ដែលនាំសិរីល្អដល់ព្រះគ្រីស្ទ គឺជារបស់យើងវិញ។

## អភ័យឯកសិទ្ធិក្នុងគ្រួសារ

ដោយសារតែយើងមានអត្តសញ្ញាណរបស់ព្រះគ្រីស្ទ នោះ យើងគឺជាសមាជិករបស់គ្រួសារនៃព្រះ (ហេព្រើរ ២:១១)។ វាមិនមានបញ្ហាអ្វីទេទោះបើយើងមានប្រវត្តិធ្វើបាប។ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ យើងមានជីវិតថ្មីនៅក្នុងព្រះគ្រីស្ទ (២កូរិនថូស ៥:១៧)។ អ្នកណាដែលរួបរួមជាមួយនឹងព្រះគ្រីស្ទ នោះ គឺជាកូនរបស់ព្រះ។ តាមរយៈ «ការទទួលជាកូនចិញ្ចឹម» នេះ ព្រះប្រទានឲ្យយើងនូវការធានាពិសេសដើម្បីជួយឲ្យយើងថ្វាយសិរីល្អដល់ព្រះគ្រីស្ទដែលដែលបានអនុញ្ញាតឲ្យយើងប្រើអត្តសញ្ញាណរួមជាមួយនឹងទ្រង់។

*ឋានៈដែលមិនផ្លាស់ប្តូរ។* ការធានាទីមួយគឺថា ឋានៈរបស់យើងមិនផ្លាស់ប្តូរទេ។ នៅពេលប្អូនប្រុសរបស់ខ្ញុំត្រូវបានកាត់ទោសសំរាប់ទោសឧក្រិដ្ឋរបស់គាត់ គេបានអនុញ្ញាតឲ្យក្រុមគ្រួសាររបស់ខ្ញុំជួបជុំជាមួយគាត់មុនពេលគេយកគាត់ទៅដាក់គុក។ ដោយទឹកភ្នែកហូរ ឪពុករបស់ខ្ញុំបានដកស្រង់បទចម្រៀងសរសើរតម្កើងចាស់មួយសំរាប់ប្អូនប្រុសរបស់ខ្ញុំដែលទើបតែបានសង្គ្រោះ ហើយដែលនឹងជាប់គុកថា៖

ហើយគុកនឹងដូចជាព្រះរាជវាំង ប្រសិនបើព្រះយេស៊ូវ នឹងគង់នៅជាមួយខ្ញុំនៅទីនោះ។[៩]

ជាមួយសំនួនសេចក្តីដ៏ទន់ភ្លន់នៃពាក្យពេជន៍ទាំងនេះ ឪពុករបស់ខ្ញុំបានបញ្ជាក់សេចក្តីស្រលាញ់របស់គាត់ ក៏ដូចជាសេចក្តីកំសាន្តចិត្តហូរចេញពីសេចក្តីស្រលាញ់របស់ព្រះអម្ចាស់សំរាប់ដាវីឌ។ ទោះបើដាវីឌបានបំបាក់មុខ និងបានក្បត់ឪពុករបស់ខ្ញុំក៏ដោយ ក៏ដាវីឌនៅតែជាកូនប្រុសរបស់គាត់ដដែល។ គ្មានអ្វីដែលដាវីឌធ្វើអាចផ្លាស់ប្តូរទំនាក់ទំនងនេះបានឡើយ។

ក្នុងរបៀបដូចគ្នានេះ សកម្មភាពរបស់យើងមិនផ្លាស់ប្តូរទំនាក់ទំនងរបស់យើងជាមួយនឹងព្រះទេ (ហេព្រើរ ១០:១៤)។ សូម្បីពេលដែលយើងធ្វើបាប ហើយក្បត់សេចក្តីស្រលាញ់របស់ទ្រង់ ក៏យើងនៅតែជាកូនរបស់ទ្រង់ដដែល។ ឋានៈខាងព្រលឹងវិញ្ញាណរបស់យើងមិនត្រូវបានកំណត់ដោយអ្វីដែលយើងធ្វើនោះទេ ប៉ុន្តែកំណត់ដោយអ្វីដែលព្រះគ្រីស្ទបានធ្វើវិញ។ ដោយសារព្រះគ្រីស្ទគង់ក្នុងយើង នោះព្រះស្រលាញ់យើង។ ការធានាអំពីសេចក្តីសប្បុរសដែលមិនចេះប្រួលប្រែរបស់ទ្រង់ផ្តល់ឲ្យយើងនូវបំណងចិត្តក្នុងការថ្វាយសិរីល្អដល់ទ្រង់ ហើយនិងការប្តេជ្ញាចិត្តក្នុងការងាកបែរមករកទ្រង់វិញនៅពេលដែលយើងធ្វើបាប (រ៉ូម ២:៤)។

ព្រះអាចដាក់វិន័យដល់យើងឲ្យយើងងាកបែរចេញពីលទ្ធផលគ្រោះថ្នាក់ដែលកើតចេញពីការបះបោររបស់យើង ប៉ុន្តែការកែទំរង់នេះមិនមែនមានន័យថាដោយសារទ្រង់ស្រលាញ់យើងតិចនោះទេ។ គោលបំណងនៃការដាក់វិន័យរបស់ព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ គឺដើម្បីជួយយើង មិនដែលចង់ធ្វើឲ្យយើងគ្រោះថ្នាក់នោះឡើយ។ សូម្បីតែពេលព្រះដាក់វិន័យខ្លាំងបំផុតមកលើយើង ក៏ទ្រង់នៅតែស្រលាញ់យើងជានិច្ច ហើយការពារយើងខាងព្រលឹងវិញ្ញាណដែរ (ហេព្រើរ ១២:៥-១១)។ ក្នុងនាមជាកូនរបស់ព្រះ ឋានៈរបស់យើងមិនផ្លាស់ប្តូរឡើយ។

*ការការពារជានិច្ច។* ដោយសារឋានៈរបស់យើងមិនផ្លាស់ប្តូរ នោះយើងក៏មានការធានាថា ទ្រង់នឹងការពារយើងជានិច្ចនោះដែរ។ ទោះបើសេចក្តីសន្យារបស់ព្រះក្នុងការការពារអាចធ្វើឲ្យអស់អ្នកដែលដឹងអំពីទុក្ករកម្មរបស់គ្រីស្ទបរិស័ទ ឬអំពីគ្រីស្ទបរិស័ទដែលបានឆ្លងកាត់ការឈឺចាប់និងសោកនាដកម្ម អស់សំណើចក៏ដោយ ប៉ុន្តែការការពាររបស់ព្រះគឺពិតប្រាកដ និង អាចទុកចិត្តបានមែន។

តើអស់អ្នកដែលរងទុក្ខលំបាកក្នុងជីវិតជាប្រចាំអាចជឿថា ព្រះនៅបន្តការពារពួកគេបានយ៉ាងដូចម្តេច? ចំលើយដែលយើងត្រូវចងចាំគឺថា ជីវិតនេះមិនមែនជាចុងបញ្ចប់នៃការរស់រានរបស់យើង ឬជាផ្នែកសំខាន់បំផុតនៃការរស់រានរបស់យើង

នោះទេ។ ព្រះយេស៊ូវបានមានបន្ទូលថា «កុំឲ្យខ្លាចចំពោះពួកអ្នកដែលសំឡាប់បានតែរូបកាយ តែពុំអាចសំឡាប់ដល់ព្រលឹងបាននោះឡើយ ស៊ូឲ្យខ្លាចព្រះអង្គវិញជាជាង ដែលទ្រង់អាចនឹងធ្វើឲ្យទាំងព្រលឹងនិងរូបកាយទៅក្នុងនរកផង» (ម៉ាថាយ ១០:២៨)។

ព្រះមានការយកព្រះទ័យទុកដាក់ខ្លាំង ក្នុងការធានាឲ្យយើងបានជីវិតអស់កល្បជានិច្ច ជាជាងធានាឲ្យជីវិតរបស់យើងមានភាពងាយស្រួល។ ដោយហេតុផលនេះ ទ្រង់ធ្វើឲ្យប្រាកដថានឹងគ្មានអ្វីចូលមកក្នុងជីវិតរបស់យើងដើម្បី បំផ្លាញឋានៈអស់កល្បរបស់យើងជាមួយទ្រង់បានឡើយ។ តើព្រះអាចស្រលាញ់យើង ដូចជាទ្រង់ស្រលាញ់ព្រះយេស៊ូវបានយ៉ាងម៉េច បើសិនជាទ្រង់អនុញ្ញាតឲ្យយើងធ្វើអ្វីមួយ ឬឆ្លងកាត់ការដែលអាចនាំឲ្យយើងធ្លាក់ចូលទៅក្នុងស្ថាននរកអស់កល្បជានិច្ច? យើងនឹងជួបប្រទះនូវទុក្ខលំបាកជាច្រើននៅក្នុងលោកិយដែលធ្លាក់ចុះនេះ (លោកុប្បត្តិ ៣:១៧-១៩) ប៉ុន្តែព្រះនឹងមិនដែលអនុញ្ញាតឲ្យការណាមួយ បំបែកទំនាក់ទំនងរបស់យើងជាមួយទ្រង់ឡើយ (រ៉ូម ៨:៣៥-៣៩)។

យើងមិនទំនងនឹងដឹងមូលហេតុជាក់លាក់សំរាប់ការល្បងលផ្សេងៗរហូតដល់ព្រះអម្ចាស់ពន្យល់ប្រាប់យើងនៅស្ថានសួគ៌ ប៉ុន្តែយើងដឹងអំពីគោលបំណងទូទៅរបស់ព្រះរួចហើយ។ សាវ័កប៉ុលសរសេរថា «គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រលាញ់ព្រះ» (រ៉ូម ៨:២៨)។ នេះគឺជាសេចក្តីសន្យាដ៏អស្ចារ្យ ព្រឹត្តិការណ៍នៃសកលលោកមិនមែនចៃដន្យនោះទេ។ ព្រះធ្វើការទាំងអស់សំរាប់សេចក្តីល្អរបស់ប្រជារាស្ត្ររបស់ទ្រង់។ សាវ័កប៉ុលបន្តបរិយាយអំពីអត្ថន័យនៃ «សេចក្តីល្អ» ។ គាត់និយាយថា គ្រប់ការទាំងអស់ផ្សំគ្នាដើម្បីធ្វើឲ្យយើងកាន់តែដូចជាព្រះបុត្រានៃព្រះ «ដើម្បីឲ្យទ្រង់បានធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន» (រ៉ូម ៨:២៩)។

ព្រះកំពុងធ្វើសកម្មភាពពង្រីក និងធ្វើឲ្យគ្រួសាររបស់ទ្រង់បានពេញវ័យឡើងដើម្បីឲ្យស្ថានសួគ៌ មានពេញទៅដោយកូនជាច្រើនដែលមានលក្ខណៈដូចជាព្រះយេស៊ូវ។ ក្នុងការស្អាងយើង(បង្ហាញដល់អ្នកដទៃទៀត)ឲ្យមានអត្តចរិត និងសេចក្តីមេត្តាករុណាដូចជាព្រះគ្រីស្ទ នោះព្រះរបស់យើងអនុញ្ញាតឲ្យយើងជួបប្រទះនឹងទុក្ខលំបាកនៅក្នុងលោកិយនេះ។ ទុក្ខលំបាកទាំងនេះផ្តាច់យើងចេញពីសេចក្តីស្រលាញ់ហួសប្រមាណចំពោះទ្រព្យសម្បត្តិដែលមិនស្ថិតស្ថេរនៅនាលោកីយនេះ ហើយជួយឲ្យយើងយល់ និងរស់នៅសំរាប់សិរីល្អដ៏លើសលប់ដែលស្ថិតស្ថេរអស់កល្បជានិច្ចរបស់ព្រះវិញ (២កូរិនថូស ៤:១៧)។ ទោះយ៉ាងណា ព្រះមិនដែលអនុញ្ញាតឲ្យមានទុក្ខលំបាកលើសពីយើងអាចទ្រាំទ្រនោះឡើយ (១កូរិនថូស ១០:១៣) មិនដែលដកវត្តមាននៃក្តីស្រលាញ់របស់ទ្រង់ឡើយ (ហេព្រើរ ១៣:៥) ហើយនៅក្នុងទុក្ខលំបាកដែលល្បងលសេចក្តីជំនឿរបស់យើង នោះជារឿយៗទ្រង់ប្រទានព្រះពរដើម្បីពង្រឹងទឹកចិត្តរបស់យើង (បរិទេវ ៣:២៣)។

ព្រះវាស់ស្ទង់ទាំងទឹកភ្នែក និងសំណើចនៅក្នុងជីវិតរបស់យើងដែលចាំបាច់សំរាប់សេចក្តីល្អដ៏នៅអស់កល្បជានិច្ចរបស់យើង (និងអ្នកជិតខាងរបស់យើង)។ យប់មួយប្អូនប្រុសរបស់ខ្ញុំដាវីឌបានសរសេរសំបុត្រពីក្នុងគុកថា «ខ្ញុំពិបាកចិត្តណាស់នៅពេលខ្ញុំគិតពីម៉ាក់និងប៉ាដែលទទួលរងនូវឈឺចាប់។ ខ្ញុំនឹងយំមួយសន្ទុះធំមុនពេលខ្ញុំអធិស្ឋានចូលគេងយប់នេះ»។ មនុស្សខ្លះសើចចំអកឲ្យសេចក្តីអធិស្ឋានទៅកាន់ព្រះមួយអង្គដែលបានអនុញ្ញាតឲ្យមានរឿងធ្វើ ឲ្យមានទឹកភ្នែកបែបនេះ។ ទឹកភ្នែករបស់ដាវីឌមិនមែនជាការបដិសេធចំពោះការងាររបស់ព្រះនៅក្នុងជីវិតរបស់គាត់នោះទេ ប៉ុន្តែជាហេតុផលដែលគាត់ត្រូវការអធិស្ឋាន។ ដាវីឌបានជឿថាព្រះនឹងធ្វើការនៅក្នុងជីវិតរបស់គាត់ ដែលពេញដោយការបះបោរ និងការឈឺចាប់ដើម្បីសំរេចឲ្យបាននូវសេចក្តីដែលប្រសើរជាង។ នៅពេលនោះដាវីឌមិនអាចដឹងអំពីសេចក្តី ប្រសើរជាងដែលព្រះកំពុងសំរេចបាននោះទេ ប៉ុន្តែគាត់នឹងដឹងក្នុងពេលឆាប់ៗ ដ្បិតព្រះក៏បើកសំដែងនូវអំណាចនៃសេចក្តីអធិស្ឋានបែបនេះ ផងដែរ។

*អំណាចផ្ទាល់ខ្លួន។* ការធានាទីបីនៃការទទួលយកជាកូនចិញ្ចឹមរបស់ព្រះ គឺជាអំណាចផ្ទាល់ខ្លួនរបស់យើង។ ព្រះបានសន្យាថា គ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ។ នេះគឺជាសេចក្តីសន្យាដ៏អស្ចារ្យ ប៉ុន្តែរឹតតែអស្ចារ្យជាងនេះទៅទៀតនោះ គឺជាមធ្យោបាយដែលទ្រង់ប្រើ។ ឧទាហរណ៍ សេចក្តីសន្យាដែលថា គ្រប់ទាំងអស់ផ្សំគ្នាសំរាប់សេចក្តីល្អរបស់យើង ត្រូវបានលើកឡើងនៅពេលដែលលោកសាវ័កប៉ុលកំពុងតែពន្យល់អំពីសេចក្តីអធិស្ឋាន។

សាវ័កប៉ុលសរសេរថា «យើងមិនដឹងជាគួរតែអធិស្ឋានសូមអ្វីទេ» (ការនេះផ្ទុយពីមនុស្សសព្វថ្ងៃខ្លះដែលធ្វើពុតជាដឹងច្បាស់អំពីអ្វីដែលត្រូវអធិស្ឋានសូម)។ បន្ទាប់មកសាវ័កប៉ុលបន្ថែមថា «តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបានវិញ...ដ្បិតព្រះវិញ្ញាណជួយអង្វរជួសពួកបរិសុទ្ធឲ្យត្រូវនឹងព្រះហឫទ័យព្រះ» (រ៉ូម ៨:២៦-២៧)។ ទោះបីជាយើងមិនដឹងគ្រប់គ្រាន់ដើម្បីនឹងទូលសូមឲ្យព្រះធ្វើអ្វីដែលល្អបំផុតក៏ដោយ ក៏ព្រះវិញ្ញាណបរិសុទ្ធបកប្រែសេចក្ដីអធិស្ឋានរបស់យើងឲ្យទៅជាការទូលអង្វរឥតខ្ចោះសំរាប់ឲ្យបំណងព្រះហឫទ័យរបស់ព្រះបានសំរេច។

នៅពេលយើងអធិស្ឋានដោយមានបំណងចិត្តឆេះឆួល កាន់តែខ្លាំងក្នុងការចង់ឃើញបំណងព្រះហឫទ័យរបស់ព្រះបានសំរេច (ប្រៀបធៀប៖ ម៉ាថាយ ៦:១០) ទ្រង់ឆ្លើយតបដោយការធ្វើឲ្យគ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្ដីល្អរបស់យើង។ ព្រះធ្វើឲ្យពិភពជុំវិញយើងមានអំណោយផលដើម្បីឲ្យអ្វីដែលល្អបំផុតខាងព្រលឹងវិញ្ញាណសំរាប់យើងកើតឡើង។ គ្រប់យ៉ាងផ្លាស់ប្ដូរដោយសារតែយើងអធិស្ឋាន មិនមែនដោយសារសេចក្ដីអធិស្ឋានរបស់យើងមានអំណាច ឬល្អនោះទេ ប៉ុន្តែដោយសារព្រះដែលយើងអធិស្ឋានទៅកាន់នោះមានអំណាច និងល្អ។

ការអះអាងរបស់ដំណឹងល្អដែលអ្នកនិពន្ធនៃព្រះគម្ពីរសញ្ញាថ្មីបានសរសេរជារឿយៗគឺថា ព្រះយេស៊ូវ គឺជាព្រះអម្ចាស់។ នេះគឺជាការប្រកាសថា ព្រះអង្គដែលបានបង្កើតរបស់សព្វសារពើបានមកដល់ហើយដើម្បីរំដោះប្រជារាស្ត្ររបស់ទ្រង់តាមរយៈអំណាចរបស់ព្រះ ដូចជាព្រះបានសន្យា (ម៉ាកុស ១:១៥ កិច្ចការ ២:៣៦, ១០:៣៦)។ អំណាចរបស់ព្រះនឹងបានបង្ហាញយ៉ាងពេញលេញ នៅពេលដែលអ្វីៗគ្រប់ទាំងអស់បានត្រលប់ទៅជាឥតខ្ចោះនៅក្នុងពេលអនាគត (ថ្ងៃដែលព្រះយេស៊ូវយាងមកវិញ) ប៉ុន្តែអំណាចរបស់ទ្រង់កំពុងបំផ្លាស់បំប្រែយើង និងស្ថានភាពក្នុងពេលបច្ចុប្បន្នរបស់យើងតាមរយៈសេចក្ដីអធិស្ឋានរបស់យើង។

គ្រួសាររបស់ខ្ញុំបានដឹងថាសេចក្ដីសន្យារបស់ដំណឹងល្អទាំងនេះមិនឥតន័យនោះទេ (អេសាយ ៦៥:២៤ អេភេសូរ ៣:២០)។ ហេតុផលមួយដែលប្អូនប្រុសរបស់ខ្ញុំដាវីឌបានយំនៅពេលគាត់គិតអំពីឪពុកម្ដាយរបស់ខ្ញុំ គឺ ការបែកបាក់គ្នារបស់ពួកគាត់ទាំងពីរ។ ភាពតានតឹងដែលកើតឡើងអស់រយៈពេលជាច្រើនទសវត្សបានជំរុញឲ្យពួកគាត់រស់នៅឆ្ងាយពីគ្នាហើយបានធ្វើឲ្យការវិនិច្ឆ័យទោសរបស់ប្អូនប្រុសរបស់ខ្ញុំកាន់តែពិបាកដោះស្រាយ។ ដូច្នេះ បន្ទាប់ពីគាត់បានប្រែចិត្តជឿលើព្រះយេស៊ូវ ដាវីឌបានចាប់ផ្ដើមអធិស្ឋានសំរាប់ឪពុកម្ដាយរបស់ខ្ញុំដែលមានវ័យចំណាស់ ដែលបានបែកគ្នាអស់រយៈពេលជិតដប់ប្រាំឆ្នាំឲ្យបានផ្សះផ្សាគ្នាវិញ។ ខ្ញុំគ្មានសេចក្ដីក្លាហាននឹងប្រាប់គាត់ថា ខ្ញុំបានគិតថាសេចក្ដីអធិស្ឋានរបស់គាត់ឥតប្រយោជន៍នោះទេ។ ប៉ុន្តែមិនយូរប៉ុន្មាន មានការកើតឡើងដែលរំលឹកខ្ញុំអំពីសេចក្ដីពិតតាមព្រះគម្ពីរ ដែលដួងចិត្តរបស់ខ្ញុំត្រូវជឿ។

ពីរបីសប្ដាហ៍មុនថ្ងៃរៀបការរបស់កូនស្រីច្បងរបស់ខ្ញុំ ម្ដាយរបស់ខ្ញុំបានទូរស័ព្ទមកប្រាប់ថា គាត់និងឪពុករបស់ខ្ញុំនឹងមកចូលរួម។ គាត់និយាយថា «យើងនឹងស្នាក់នៅក្នុងសណ្ឋាគារតែមួយក្នុងបន្ទប់តែមួយ»។ ខណៈនោះខ្ញុំ ភ្ញាក់ព្រើត និងនៅស្ងៀមអត់មាត់អត់ក បន្ទាប់មកគាត់ខ្សឹបប្រាប់ថា «វាមិនមែនជារឿងអាស្រូវនោះទេ។ ចាំទេថា ពួកយើងទាំងពីរនៅជាប្ដីប្រពន្ធនៅឡើយ មិនទាន់លែងលះគ្នាទេ»។

ខ្ញុំបានសួរថា «ម៉ាក់ តើអ្វីៗគ្រប់យ៉ាងរវាងម៉ាក់ និងប៉ាបានល្អប្រសើរឡើងវិញហើយឬ?»

គាត់ឆ្លើយដោយទឹកភ្នែកថា «តាមរយៈការដោះស្រាយទុក្ខលំបាករបស់ប្អូនប្រុសរបស់ឯង ប៉ារបស់ឯងនិងម៉ាក់បានរៀនពឹងពាក់គ្នាទៅវិញទៅមកជាថ្មីឡើងវិញ »។ បន្ទាប់មកខ្ញុំបានយំខ្សឹកខ្សួលហើយស្ញើចសរសើរព្រះដែលធ្វើគ្រប់ការទាំងអស់សំរាប់សេចក្ដីល្អ ហើយប្រើការធម្មតារបស់លោកិយនេះដើម្បីធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ (១កូរិនថូស ១:២៧)។ ខ្ញុំគួរតែរំពឹងថាព្រះរបស់ខ្ញុំនឹងឆ្លើយតបហួសពីការគិតរបស់ខ្ញុំទៅទៀត។ ប៉ុន្តែប្អូនប្រុសរបស់ខ្ញុំដែលអសមត្ថភាពខាងសតិបញ្ញា បានប្រព្រឹត្តបទឧក្រិដ្ឋ ជាប់គុក បានជឿលើព្រះបន្ទូលរបស់ព្រះ ហើយបានអធិស្ឋានសូមជំនួយរបស់ព្រះ ហើយព្រះបានឆ្លើយតប។

ឥឡូវនេះពេលឪពុកម្ដាយខ្ញុំដែលមានអាយុចិតសិបប្រាំបួនឆ្នាំ និងប៉ែតសិបពីរឆ្នាំមកសួរសុខទុក្ខប្អូនប្រុសរបស់ខ្ញុំក្នុងគុក ពួកគេតែងដើរចូលតាមទ្វារព័ទ្ធបន្លាលួសដោយកាន់ដៃគ្នា។ ហើយខ្ញុំនិយាយទៅកាន់អ្នកទាំងអស់ដែលជឿជាមួយខ្ញុំថា «ដំណឹងល្អ គឺការពិត ដំណឹងល្អផ្លាស់ប្ដូរពិភពលោក»។ ខ្ញុំ មិនសន្យាថាព្រះនឹងឆ្លើយតប ចំពោះការទូលសូមជាក់លាក់ណាមួយរបស់យើង ឬថាយើងនឹងតែងតែមើលឃើញលទ្ធផលនៃសេចក្ដីអធិស្ឋាននៅក្នុងជីវិតរបស់យើងគ្រប់ពេលវេលានោះទេ ប៉ុន្តែដោយសារព្រះគម្ពីរសន្យា នោះខ្ញុំនឹងសន្យាថា ព្រះនឹងធ្វើគ្រប់ការទាំងអស់សំរាប់សេចក្ដីល្អរបស់អស់អ្នកដែលស្រលាញ់ទ្រង់។

*ការរីកចំរើនខាងព្រលឹងវិញ្ញាណ។* អំណាចដែលយើងទទួលដោយព្រោះព្រះអង្គទទួលយើងជាកូនចិញ្ចឹម មិនត្រឹមតែមានឥទ្ធិពលទៅលើពិភពខាងក្រៅខ្លួនរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែទៅលើអ្វីដែលស្ថិតនៅក្នុងខ្លួនយើងផងដែរ។ គ្រីស្ទបរិស័ទមិនអធិស្ឋានអស់ពីចិត្តសំរាប់អ្វីផ្សេងទៀតជាជាងអធិស្ឋានសូមឲ្យជីវិតរបស់ពួកគេបានថ្វាយសិរីល្អដល់ព្រះអង្គសង្គ្រោះរបស់ខ្លួននោះទេ។ ទោះយ៉ាងណា សេចក្ដីល្បួងនៅតែឡោមព័ទ្ធចាប់យើង ហើយជារឿយៗយើងចុះចាញ់ដោយសារភាពកម្សោយខាងវិញ្ញាណរបស់យើង។ សំរាប់ការតយុទ្ធនេះ ដំណឹងល្អនាំមកនូវការធានាទីបួនសំរាប់កូនរបស់ព្រះ ព្រះប្រទានឲ្យយើងនូវធនធានពីខាងក្នុងដើម្បីប្រយុទ្ធជាមួយអំពើបាប។

ដំណើរនៃការរីកចំរើនធំធាត់ឡើងឲ្យដូចជាព្រះគ្រីស្ទត្រូវបានហៅថា «ការញែកជាបរិសុទ្ធ»។ មានរបៀបមួយចំនួនដែលព្រះបន្ទូលរបស់ព្រះជួយឲ្យយើងពេញវ័យនៅក្នុងព្រះគ្រីស្ទ។ ទីមួយ ព្រះគម្ពីរប្រាប់យើងអំពី អ្វីដែលព្រះចង់ឲ្យយើងធ្វើ។ ព្រះមិនជំរុញឲ្យយើងទាយនោះទេ។ ផ្ទុយទៅវិញ ព្រះប្រទានឲ្យយើងនូវសេចក្ដីបង្រៀនដែលរក្សាយើងឲ្យមានសុវត្ថិភាពខាងវិញ្ញាណ ហើយនិងបំពេញសំរេចបំណងចិត្តរបស់យើងក្នុងការថ្វាយសិរីល្អដល់ទ្រង់។ ខណៈពេលដែលលោកិយគិតថាក្រឹត្យវិន័យរបស់ព្រះគឺជាអ្វីមួយដែលបញ្ឈប់យើងពីភាពរីករាយ គ្រីស្ទបរិស័ទយល់ថា សេចក្ដីបង្គាប់របស់ព្រះនាំយើងនៅក្នុងផ្លូវដែលគាប់ព្រះហឫទ័យទ្រង់ និងធ្វើឲ្យចិត្តរបស់យើងបានស្កប់។

ដើម្បីកុំឲ្យយើងដើរតាមសេចក្ដីបោកបញ្ឆោតរបស់លោកិយ ព្រះក៏ប្រាប់យើងឲ្យរៀននូវព្រះបន្ទូលរបស់ទ្រង់ ទាក់ទងនិងសេចក្ដីអធិស្ឋាន ការថ្វាយបង្គំជាមួយប្រជារាស្ត្ររបស់ទ្រង់ ហើយនិងការស្វែងរកការប្រឹក្សាយោបល់ពីអស់អ្នកដែលពេញវ័យក្នុងផ្លូវរបស់ព្រះ។ តាមរយៈការ ប្រើប្រាស់នូវ "មធ្យោបាយនៃការប្រទានព្រះគុណ"ទាំងនេះយ៉ាងទៀងទាត់ យើងនឹងរីកចំរើនខាងឯការគោរពកោតខ្លាចព្រះអម្ចាស់។ ក្នុងកំរិតខ្លះ មធ្យោបាយទាំងនេះដែលព្រះអង្គប្រើដើម្បីប្រទានព្រះគុណមានប្រសិទ្ធិភាព ពីព្រោះយើងឆ្លើយតបនឹងដំណើរការនៃការ ការអប់រំ និងការបំផ្លាស់បំប្រែឥរិយាបថ។ បើសិនជាយើងស្រេកទឹក នោះទឹកមួយកែវនឹងជួយយើងឲ្យបាត់ស្រេកបាន បើសិនជាយើងកំពុងតយុទ្ធជាមួយសេចក្ដីល្បួង នោះការប្រឹក្សាយោបល់តាមព្រះគម្ពីរនឹងជួយឲ្យយើងអាចជៀសផុតបាន។

ព្រះគម្ពីរនិយាយថា ការតយុទ្ធខាងវិញ្ញាណរបស់យើងមិនមែននឹងសាច់ឈាមទេ គឺនឹងវិញ្ញាណអាក្រក់ដែលនៅក្នុងនិងក្រៅខ្លួនយើង (អេភេសូរ ៦:១២)។ ការតយុទ្ធទាំងនេះត្រូវការការ ទប់ទល់ដែលមានកំលាំងខ្លាំងជាងកំលាំងផ្ទាល់ខ្លួនរបស់យើងទៅទៀត។ ដូច្នេះ ព្រះអម្ចាស់ក៏ប្រើមធ្យោបាយ នៃការប្រទានព្រះគុណទាំងនេះ ដើម្បីប្រទានឲ្យយើងនូវអំណាចរបស់ព្រះ ដែលនឹងជួយឲ្យយើងអាចឈ្នះការប្រយុទ្ធទាំងនេះ។

អំណាចខាងព្រលឹងវិញ្ញាណចូលមកក្នុងជីវិតរបស់យើងតាមរយៈសេចក្ដីជំនឿក្នុងជីវិតថ្មី ដែលព្រះបន្ទូលរបស់ព្រះហៅថាស្នាព្រះហស្តថ្មី នៅក្នុងព្រះគ្រីស្ទយេស៊ូវ។ មុនពេលវត្តមានរបស់ព្រះគ្រីស្ទនៅក្នុងចិត្តរបស់យើង នោះយើងមិនអាចជៀសផុតពីការធ្វើបាបបានទេ។ ប៉ុន្តែព្រះយេស៊ូវបំផ្លាស់បំប្រែយើង។ ទ្រង់ប្រទានព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ឲ្យមកគង់ក្នុងចិត្តរបស់យើងដើម្បីឲ្យយើងទទួលស្គាល់អំពើបាបរបស់យើង (ឧទាហរណ៍ ជួយឲ្យយើងជឿថាអំពើបាបគឺជាអំពើខុសឆ្គង) ហើយប្រទានអំណាចឲ្យយើងទប់ទល់នឹងការល្បួង និងសាតាំង (កូល៉ុស ១:១៣)។ សាវ័កយ៉ូហានសរសេរថា «ព្រះដែលគង់ក្នុងអ្នករាល់គ្នា (ព្រះវិញ្ញាណបរិសុទ្ធ) នោះទ្រង់ធំជាងអានោះដែលនៅក្នុងលោកិយផង (សាតាំង)»

(១យ៉ូហាន ៤:៤)។ ព្រះវិញ្ញាណដដែលដែលបានប្រោសព្រះយេស៊ូវឲ្យរស់ពីការសុគតឡើងវិញ គង់ក្នុងយើង ហើយប្រទានអំណាចឲ្យយើងយកឈ្នះអំពើបាបបាន។

សាតាំងនឹងនៅតែព្យាយាមធ្វើឲ្យយើងជឿថា ការបរាជ័យ គឺជារឿងធម្មតា ហើយថាយើងគ្មានផ្លូវ អាចទប់ទល់នឹងអំពើបាបបានទេ។ តែព្រះបន្ទូលព្រះប្រកាសថា យើងអាចទប់ទល់បានដោយព្រោះយើងលែងពឹងផ្អែកលើកំលាំងផ្ទាល់ខ្លួនរបស់យើងតែមុខទៀតហើយ (រ៉ូម ៨:១១)។ ជាការពិតណាស់ បើសិនយើងមិនជឿថាយើងអាចមានជ័យជំនះបាន នោះយើងបានចាញ់ការប្រយុទ្ធបាត់ទៅហើយ។ ដូច្នេះហើយបានជា សេចក្តីជំនឿលើសេចក្តីពិតនៃព្រះបន្ទូលព្រះ គឺជាការចាប់ផ្តើមនៃជ័យជំនះខាងវិញ្ញាណ។ ការប្រើមធ្យោបាយដែលព្រះអង្គប្រើដើម្បីប្រទានព្រះគុណ(ដូចព្រះបន្ទូល)យ៉ាងទៀងទាត់ជួយឲ្យសេចក្តីជំនឿរបស់យើងរីកចំរើន។

*សុវត្ថិភាពខាងព្រលឹងវិញ្ញាណ*។ មធ្យោបាយដែលព្រះអង្គប្រើដើម្បីប្រទានព្រះគុណ ក៏ដាំក្នុងជំរៅចិត្តយើងនូវ ជំនឿយ៉ាងមុតមាំថា បើទោះជាយើងមិនឈ្នះរាល់ការតយុទ្ធទាំងអស់ក៏ដោយ ក៏ព្រះនៅតែស្រលាញ់យើងដដែល។ មិត្តភ័ក្តិម្នាក់របស់ខ្ញុំសរសេរដោយប្រាជ្ញាវ័យឆ្លាតថា «មនុស្សដែលរីកចំរើនខាងវិញ្ញាណ គឺជាអស់អ្នកដែលដឹងថា បើទោះជាពួកគេមិនរីកចំរើនខាងវិញ្ញាណ ក៏ព្រះនៅតែស្រលាញ់ពួកគេមិនតិចជាងមុនដែរ»។ ស្តាប់ទៅហាក់បីដូចជារឿងមួយដែលមិនអាចទៅរួចទេ។ បើសិនជាមនុស្សដឹងថាការបរាជ័យរបស់ពួកគេមិនកាត់បន្ថយសេចក្តីស្រលាញ់របស់ព្រះ អញ្ចឹងតើពួកគេនឹងបន្តដេកននៀលនៅក្នុងអំពើបាបរបស់គេទៀត ឬមួយយ៉ាងណា ? មនុស្សបះបោរខ្លះចង់ប្រើព្រះគុណ ធ្វើជាហេតុផលក្នុងការធ្វើបាប ប៉ុន្តែមនុស្សដែលចុះចូលនឹងវិញ្ញាណនៃព្រះមិនគិតដូច្នេះ នោះទេ។

មុនយើងអាចយល់អំពីរបៀបដែលសេចក្តីស្រលាញ់ដ៏នៅឋិតថេររបស់ព្រះបង្កើននូវភាពបរិសុទ្ធ យើងត្រូវការពិចារណាអំពីសំនួរសំខាន់មួយ៖ «តើអ្វីដែលផ្តល់អំណាចដល់អំពើបាបនៅក្នុងជីវិតរបស់អ្នក?» ចំលើយគឺ «អំពើបាបមានអំណាចនៅក្នុងជីវិតរបស់អ្នកពីព្រោះអ្នកចូលចិត្តវា»។ បើសិនជាអំពើបាបមិនទាក់ទាញអ្នកនោះទេ នោះវានឹងគ្មានអំណាចក្នុងការល្បួងអ្នកនោះឡើយ។ ឥឡូវមានសំនួរមួយទៀត៖ «តើអ្វីគឺជាផ្លូវតែមួយក្នុងការប្រើសេចក្តីស្រលាញ់ ដើម្បីបណ្តេញអំពើបាប?» ចំលើយគឺ៖ «ដោយសេចក្តីស្រលាញ់ដែលធំជាង»។ នៅពេលយើងស្រលាញ់ព្រះយេស៊ូវខ្លាំងជាងអំពើបាប នោះយើងចង់ផ្គាប់ព្រះទ័យទ្រង់ខ្លាំងជាងយើងចង់ធ្វើតាមបំណងចិត្តបាបរបស់យើង (យ៉ូហាន ១៤:១៥)។ សេចក្តីស្រលាញ់សំរាប់ព្រះយេស៊ូវដេញសេចក្តីស្រលាញ់សំរាប់ការអាក្រក់ដែលផ្តល់អំណាចដល់អំពើបាបចេញពីជីវិតរបស់យើង។

ហើយឥឡូវសំនួរមួយចុងក្រោយ៖ តើអ្វីធ្វើឲ្យអ្នកស្រលាញ់ព្រះយេស៊ូវ? ម្តងទៀតព្រះគម្ពីរឆ្លើយថា៖ «យើងស្រលាញ់ទ្រង់ ពីព្រោះទ្រង់បានស្រលាញ់យើងជាមុន» (១យ៉ូហាន ៤:១៩)។ ឥឡូវយើងដឹងថាហេតុអ្វីបានជាពាក្យដែលថា « បើសិនជាព្រះស្រលាញ់យើងដោយមិនគិតពីអំពើបាបរបស់យើង នោះ នឹងលើកទឹកចិត្តយើងឲ្យធ្វើបាបកាន់តែខ្លាំង» មិនមែនជាការពិតទេ។ នៅពេលដែលយើងពិតជាស្រលាញ់ទ្រង់ យើងចង់ផ្គាប់ព្រះទ័យទ្រង់។ ហើយអ្វីដែល ជំរុញឲ្យយើងចង់ផ្គាប់ព្រះទ័យទ្រង់ខ្លាំងបំផុត គឺជាការដឹងថាសេចក្តីស្រលាញ់មិនប្រួលប្រែរបស់ព្រះអម្ចាស់មិនចេះផុតឡើយ(បរិទេវ ៣:២២-២៣)។ ព្រះគុណដែលអត់ធន់របស់ទ្រង់ចំពោះកូនៗរបស់ទ្រង់គឺជាអំណាចជំរុញឲ្យមានភាពបរិសុទ្ធនៅក្នុងចិត្តរបស់យើង (រ៉ូម ១២:១-៣)។

ភ្លាមៗបន្ទាប់ពីគាត់ជាប់គុក ដាវីឌបានចាប់ផ្តើមផ្ញើរសំបុត្រឲ្យពួកយើងដែលនៅក្នុងសំបុត្រនោះ គាត់បានសរសេរចំឡងខគម្ពីរហើយ និងពាក្យចម្រៀងសរសើរតម្កើងដែលក្រុមអធិស្ឋានរបស់គាត់បានច្រៀង។ គាត់ក៏បានចាប់ផ្តើមបញ្ចប់សំបុត្រនីមួយៗរបស់គាត់ដោយសរសេរថា «សូមព្រះប្រទានពរ»។ ថ្វីបើគាត់នៅក្នុងគុក មានសេចក្តីល្បួង និងទុក្ខធំជាងអ្វីដែលខ្ញុំអាចស្រមៃឃើញ ក៏គាត់យល់ថាគាត់ គឺជាឧបករណ៍មួយសំរាប់ការប្រកាសនូវសិរីល្អរបស់ព្រះដែរ។ គាត់ចង់ឲ្យជីវិតរបស់គាត់បានបង្ហាញអំពីព្រះគុណដែលគាត់បានទទួល។ គ្មាននរណាបង្ខំគាត់ឲ្យសរសេរពាក្យទាំងនោះនោះទេ

ហើយក៏គ្មាននរណាម្នាក់អាចបង្ខំគាត់បានដែរ។ ប៉ុន្តែសេចក្តីស្រលាញ់របស់គាត់ចំពោះព្រះយេស៊ូវត្រឡប់ជាកំលាំងជំរុញចិត្តរបស់គាត់។ សេចក្តីនេះដូចគ្នានឹងអស់អ្នកដែលស្គាល់សេចក្តីស្រលាញ់ដ៏ឥតលក្ខខ័ណ្ឌ និងព្រះគុណដែលមិនចេះផុតរបស់ព្រះគ្រីស្ទដែរ។

*មរតកដ៏អស់កល្បជានិច្ច*។ ការធានាទីប្រាំរបស់កូនៗនៃព្រះ គឺជាការទទួលមរតករបស់ពួកគេ (អេភេសូរ ១:១៤, ២:៧)។ ព្រះគម្ពីរនិយាយថា កូនៗចិញ្ចឹមរបស់ព្រះ គឺជាអ្នកទទួលមរតករួមជាមួយព្រះគ្រីស្ទ (រ៉ូម ៨:១៧)។ មានតែចំនុចសំខាន់ៗពីរបីនៅក្នុងដំណឹងល្អនេះ ដែល អាចលើកមកនិយាយនៅក្នុង សេចក្តីសង្ខេបខ្លីនេះ។ ទីមួយ គឺជីវិតអស់កល្បជានិច្ច។ នៅពេលពួកអ្នកជឿស្លាប់ ព្រលឹងរបស់ពួកគេនឹងចូលទៅក្នុងព្រះវត្តមានរបស់ព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ មួយរំពេច (១កូរិនថូស ៥:៨; ភីលីព ១:២១-២៤)។ ការទទួលយកពេញលេញ សេចក្តីអំណរពេញលេញ ហើយនិងសន្តិភាពពេញលេញនឹងក្លាយជារបស់យើងភ្លាម ប៉ុន្តែ រឿងនេះមិនទាន់ចប់ត្រឹមនេះនោះទេ (លូកា ២៣:៤៣)។ ថ្ងៃមួយព្រះគ្រីស្ទនឹងយាងមក ហើយនឹងកែផែនដីដែលទ្រង់បានបង្កើតពីដំបូងយ៉ាងល្អប្រពៃ ជាថ្មីឡើងវិញ (អេសាយ ៦៥:១៧-១៩ រ៉ូម ៨:២១-២៣)។ ព្រះនឹងស្តារគ្រប់ទាំងព្រះពរទាំងអស់ដែលមនុស្សមាននៅក្នុងសួនច្បារអេដែនកាលពីដំបូងឡើងវិញ គឺជាពិភពលោកដែលពេញទៅដោយការផ្គត់ផ្គង់របស់ព្រះ ហើយគ្មានការរងទុក្ខវេទនា (វិវរណៈ ២១:៤)។

របស់សព្វសារពើនឹងត្រូវបានស្តារឡើងវិញ ហើយយើងនឹងបានកែជាថ្មីទាំងនៅក្នុងវិញ្ញាណ រូបកាយ និងគំនិត (១កូរិនថូស ១៥:៥២-៥៤)។ ប្អូនប្រុសដែលជាប់គុករបស់ខ្ញុំមិនត្រឹមតែនឹងទទួលបានការអត់ទោសដ៏ពេញលេញរបស់ព្រះនោះទេ ប៉ុន្តែរូបកាយរបស់គាត់នឹងបានបរិសុទ្ធម្តងទៀត ហើយនោះគឺជាពេលតំបូងបង្អស់ដែលគាត់នឹងមានសតិបញ្ញាប្រក្រតីឡើងវិញ ។ ប្អូនប្រុសរបស់ខ្ញុំនឹងមានសិរីល្អជាងពួកទេវតាទៅទៀត (១យ៉ូហាន ៣:២-៣)។ គាត់នឹងដើរដោយសេរីភាពនៅក្នុងការ បង្កើតថ្មីដោយគ្មានក្តីអាម៉ាស់ ភ្នែករបស់គាត់នឹងមានពន្លឺភ្លឺថ្លា ហើយចិត្តរបស់គាត់នឹងរីករាយជាមួយសោភ័ណភាពដែលនៅជុំវិញគាត់។ ក្រុមគ្រួសាររបស់ខ្ញុំ អស់អ្នកដែលបានលាចាកលោកនេះ ទៅហើយ ហើយនិងអស់អ្នកដែលព្រះនឹងបន្តត្រាស់ហៅឲ្យចូលទៅក្នុងស្ថានសួគ៌ នឹងបានជួបជុំគ្នាវិញជាមួយគាត់ និងអស់អ្នកដែលស្រលាញ់ព្រះយេស៊ូវ (១ថេស្សាឡូនិច ៤:១៤-១៨)។ យើងនឹងស៊ីលៀងនៅលើតុរបស់ព្រះអម្ចាស់ ត្រេកអរនឹងសេចក្តីល្អរបស់ទ្រង់ ហើយរីករាយជាមួយនឹងពិភពលោកដ៏ឥតខ្ចោះដែលបង្កើតដោយព្រះគុណនៃព្រះរបស់យើងអស់កល្បជានិច្ច។ ព្រះអង្គដែលបានយាងមកសង្គ្រោះមនុស្សមានបាបប្រទានសេចក្តីសង្គ្រោះមួយយ៉ាងធំអស្ចារ្យដែល ស្តារផែនដីទាំងមូលឡើងវិញ បានសង្គ្រោះទាំងរូបកាយ និងព្រលឹងវិញ្ញាណរបស់យើង ឲ្យនៅស្ថិតស្ថេរ អស់កល្បជានិច្ច (វិវរណៈ ២១:១)។

## *ព្រះប្រើអ្នកណាដែលទ្រង់បន្សុទ្ធយ៉ាងឥតខ្ចោះ៩*

### គោលបំណងសំរាប់បុគ្គល

សេចក្តីស្រលាញ់ដ៏អស្ចារ្យរបស់ព្រះគ្រីស្ទសំរាប់ប្រជារាស្ត្ររបស់ទ្រង់ ហើយនិងពិភពលោករបស់ពួកគេដែលបានបង្ហាញឲ្យឃើញតាមរយៈការប្រោសលោះទាំងពីរ មានឥទ្ធិពលខ្លាំងលើអស់អ្នកដែលស្រលាញ់ទ្រង់។ ដោយព្រោះយើងស្រលាញ់ទ្រង់ នោះយើងក៏ស្រលាញ់អ្វី និងអ្នកដែលទ្រង់ស្រលាញ់ផងដែរ។ ភ្លាមៗបន្ទាប់ពីការប្តេជ្ញារបស់គាត់ចំពោះព្រះគ្រីស្ទ ប្អូនប្រុសរបស់ខ្ញុំដាវីឌដែលពីមុនបានប្រមាថព្រះតាមរយៈពាក្យសំដីនិងទង្វើររបស់គាត់ បានសរសេរថា «ខ្ញុំស្រលាញ់ព្រះយេស៊ូវខ្លាំងណាស់ ដូច្នេះឥឡូវនេះខ្ញុំមិនអាចទ្រាំបានទេ នៅពេលមនុស្សបញ្ចេញព្រះនាមទ្រង់ជាអសារឥតការ។ ខ្ញុំចង់ឲ្យពួកគេដឹងថាទ្រង់ល្អប៉ុណ្ណា»។ នៅពេលព្រះយេស៊ូវគង់ក្នុងយើង នោះចិត្តរបស់ទ្រង់ត្រឡប់ជាចិត្តរបស់យើង (រ៉ូម ៦:៤-១១)។

មនុស្សដែលស្រលាញ់ព្រះយេស៊ូវ ចង់ផ្គាប់ព្រះទ័យទ្រង់តាមរយៈការស្រលាញ់អស់អ្នកដែលទ្រង់ស្រលាញ់។ យើងមានអំណរក្នុងការធ្វើជាទូតរបស់ទ្រង់ទៅកាន់អ្នកដែលបាត់បង់ ធ្វើជាព្រះហស្តរបស់ទ្រង់សំរាប់អ្នកដែលខ្វះខាត ធ្វើជា

សំឡេងរបស់ទ្រង់សំរាប់អ្នកដែលត្រូវគេ សង្កត់សង្កិន និងជាអ្នកថែរក្សាការពាររបស់សព្វសារពើដែលទ្រង់បានប្រទានដល់មនុស្សជាតិ។ យើងមានអំណរដែលគ្រួសាររបស់ទ្រង់ពង្រីកលើសពីព្រំដែន ជាតិសាសន៍របស់មនុស្ស តំបន់ ឋានៈ និងវប្បធម៌ ហើយយើងមានចិត្តត្រេកអរនឹងស្រលាញ់ពួកគេដូចជាព្រះបានស្រឡាញ់យើងយ៉ាងនោះដែរ។ ហើយនៅពេលយើងបង្ហាញសេចក្តីស្រលាញ់របស់ព្រះគ្រីស្ទនៅក្នុងខ្លួនយើង នោះយើងដែលកាលពីមុនត្រូវការសេចក្តីសង្គ្រោះបានស្វែងរកឃើញនូវទិដ្ឋភាពចុងក្រោយនៃសេចក្តីសង្គ្រោះរបស់ព្រះគ្រីស្ទ៖ គោលបំណងនៃជីវិត ដែល មកពីព្រះ។

យើងត្រូវបានសង្គ្រោះឲ្យរួចពីជីវិតឥតន័យ ក៏ដូចជាចេញពីជីវិតដែលមានបាបផងដែរ (១ពេត្រុស ១:១៨)។ ព្រះយេស៊ូវធ្វើឲ្យអ្វីដែលបាក់បែកទៅហើយត្រឡប់ជាមានប្រយោជន៍វិញ។ ព្រះយេស៊ូវមិនទាន់លែងប្រើបុរសដែលមានទោសហើយត្រូវជាប់គុកជាមួយប្អូនប្រុសរបស់ខ្ញុំនោះទេ ។ ដោយសារតែបុរសដែលមានជាតិសាសន៍ផ្សេងម្នាក់នេះបានចែកចាយសេចក្តីជំនឿជាមួយប្អូនប្រុសរបស់ខ្ញុំ ទើបពួកគេទាំងពីរបានស្គាល់សេចក្តីស្រលាញ់របស់ព្រះគ្រីស្ទ ហើយបានក្លាយជាបងប្អូនខាងព្រលឹងវិញ្ញាណដ៏នៅអស់កល្បជានិច្ច។

ម្តងហើយម្តងទៀតប្អូនប្រុសពិការរបស់ខ្ញុំត្រូវបាន ពួកបុរសនៅក្នុងគុកដែលមានជាតិសាសន៍ ឬជីវប្រវត្តិខុសៗគ្នាដែលយើងអាចនិយាយបានថា ពួកគេគ្មានផ្លូវនឹងបានជួបគ្នាទេ បើពួកគេរស់នៅក្នុងសង្គមខាងក្រៅនោះ ជួយមើលថែ ហើយនៅពេលដាវីឌបានរៀនអំពីសេចក្តីស្រលាញ់របស់ព្រះដែលមានទំហំធំជាងការប្រកាន់ពូជសាសន៍របស់គាត់ នោះគាត់បានក្លាយជាឧបករណ៍មួយនៃសេចក្តីស្រលាញ់របស់ព្រះសំរាប់អ្នកដទៃផងដែរ។ ការទុកចិត្ត និងមិត្តភាពជាមួយអស់អ្នកដែលខុសពី គាត់ នោះបានធ្វើ គុកមានពេញទៅដោយសិរីល្អនៃភាពជាបងប្អូនក្នុងនគរឋានសួគ៌ដែលស្ថិតស្ថេរអស់កល្បជានិច្ច។

## គោលបំណងសំរាប់ក្រុម

យើងមានចំណែកក្នុងគោលបំណងនៃការបំផ្លាស់បំប្រែរបស់ព្រះគ្រីស្ទក្នុងលក្ខណៈជាបុគ្គល ប៉ុន្តែក៏ក្នុងលក្ខណៈជាក្រុមផងដែរ។ តាមរយៈពួកជំនុំ យើងប្រកាសដំណឹងល្អរបស់ព្រះគ្រីស្ទតាមរយៈពាក្យសំដី និងការប្រព្រឹត្ត ដើម្បីឲ្យការគ្រប់គ្រងរបស់ទ្រង់រីកផ្សាយពីចិត្តមួយទៅចិត្តមួយរហូតដល់គ្រប់ជាតិសាសន៍ទាំងអស់ (កូល៉ុស ១:២២-២:៤)។ នគររបស់ទ្រង់ គឺជារឿងមួយដែលព្រះគម្ពីរបានលាតត្រដាងចាប់តាំងពីទំព័រទីមួយ។ ព្រះរបស់យើងនឹងមិនទុកឲ្យរបស់សព្វសារពើដែលឈឺចាប់បន្តរស់នៅក្នុងការឈឺចាប់នោះទេ។ ថ្វីបើការក្បត់របស់យើងបាននាំ ឲ្យផែនដី និងអ្នករស់នៅក្នុងផែនដីបាក់បែកក៏ដោយ ក៏ ព្រះរបស់យើងមិនដែលបោះបង់ផែនដី ឬមនុស្សចោលនោះឡើយ។ ទ្រង់ប្រោសលោះមនុស្សដើម្បីឲ្យពួកគេបានដឹង ហើយពង្រីកព្រះគុណរបស់ទ្រង់។ ដូច្នេះ សេចក្តីសង្គ្រោះដែលទ្រង់បាននាំមក គឺសំរាប់ មនុស្សមានបាប ហើយផ្សាយចេញតាមរយៈ មនុស្សមានបាប។ យើងប្រជុំគ្នាក្នុងពួកជំនុំដើម្បីសរសើរតម្កើងទ្រង់ ដោយព្រោះសេចក្តីល្អនេះ ដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងការរស់នៅសំរាប់ទ្រង់ ហើយដើម្បីជួយអ្នកដទៃឲ្យយល់ និងភ្លក់មើលសេចក្តីស្រលាញ់ដែលមានអំណាចក្នុងការបំផ្លាស់បំប្រែជីវិតរបស់ទ្រង់។

រឿងបុរាណស្តីអំពីសេចក្តីសង្គ្រោះដែលបានលាតត្រដាងនេះ គឺសំរាប់យើង រួមបញ្ចូលទាំងយើង។ យើងមានគោលបំណងក្នុងជីវិតដែលមិនត្រឹមតែសំរាប់ខ្លួនរបស់យើងនោះទេ ហើយក្នុងការបំពេញសំរេចគោលបំណងនេះជាមួយអ្នកដទៃ យើងអបអរសាទរចំពោះអត្តសញ្ញាណថ្មីរបស់ក្រុមយើងជាមួយបងប្អូននៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ។ ទ្រង់ប្រទានឲ្យយើងនូវអភ័យឯកសិទ្ធិក្នុងការបំពេញការងារថ្វាយទ្រង់ជាក្រុម ហើយមានចំណែក ក្នុងការពង្រីកនគររបស់ទ្រង់ ដែលបំផ្លាស់បំប្រែគ្រប់ទាំងអស់សំរាប់សិរីល្អរបស់ទ្រង់ (អេភេសូរ ១:២១)។ នៅពេលយើងរស់នៅក្នុងសហគមន៍ដែលលើកទឹកចិត្ត បង្ហាត់បង្រៀន ពង្រឹង និងអត់ទោសឲ្យគ្នាទៅវិញទៅមក យើងត្រឡប់ជាអំបិល និងពន្លឺដែលបំផ្លាស់បំប្រែលោកិយ (ម៉ាថាយ ៥:១៣-១៦ អេភេសូរ ៣:១០-២១)។

## គោលបំណងប្រោសលោះ

ព្រះសង្គ្រោះយើងដើម្បីឲ្យយើងមានឯកសិទ្ធិពិសេសក្នុងការចូលរួមចំណែកក្នុងការងារបំផ្លាស់បំប្រែរបស់ព្រះគ្រីស្ទ ហើយសំរាប់គោលបំណងដ៏ធំនេះ យើងថ្វាយកិត្តិយស ដល់ស្តេចរបស់យើង ហើយបញ្ចាំងនូវព្រះគុណរបស់ទ្រង់ ក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង ទំនាក់ទំនងរបស់យើង អាជីពរបស់យើង ការកំសាន្តរបស់យើង និងការថ្វាយបង្គំរបស់យើង។ យើងមិនអាចទុកឲ្យផ្នែកណាមួយនៃជីវិតរបស់យើង លាក់បាំងនូវសិរីល្អរបស់ទ្រង់នោះទេ ខណៈពេលដែលទ្រង់ពង្រីករាជ្យរបស់ទ្រង់នៅលើជីវិតយើងទាំងមូល។

ព្រះគ្រីស្ទយកព្រះទ័យទុកដាក់លើគ្រប់ផ្នែកទាំងអស់នៃជីវិត។ ទ្រង់គឺជាព្រះអម្ចាស់ដែលបានយាងមក ហើយនឹងយាងមកម្តងទៀតដើម្បីពង្រីកការសោយរាជ្យប្រកបដោយព្រះគុណរបស់ទ្រង់លើទាំងអស់។ ទ្រង់សង្គ្រោះយើងដើម្បីឲ្យយើងក្លាយជារបស់ទ្រង់។ ដោយព្រោះការថ្វាយគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើងទៅទ្រង់ គឺជាការស្ថប់ចិត្តធំបំផុតរបស់យើង នោះទ្រង់សព្វព្រះទ័យនឹងប្រើយើងសំរាប់គោលបំណងអស់កល្បជានិច្ច ហើយនឹងប្រោសលោះលោកិយតាមរយៈការខិតខំជាបុគ្គល និងជាក្រុម។ នៅពេលអ្នកនិពន្ធកណ្ឌដំណឹងល្អ ប្រកាសដំណឹងល្អអំពីព្រះយេស៊ូវ ពួកគេបានប្រកាសថាព្រះអម្ចាស់លើទាំងអស់បានមកដល់ហើយ។ គ្មានអំណាវណាអាចចូលរួមអបអរចំពោះការប្រកាសនេះបានទេ បើសិនជាការប្រកាសនេះ មានន័យថាជាការចាប់ផ្តើមនៃការគ្រប់គ្រងរបស់ស្តេចអាក្រក់នោះ។ ប៉ុន្តែ បើសិនជាស្តេចនោះយាងមកដើម្បីសង្គ្រោះពួកមនុស្សមានបាប ហើយបើសិនជាសេចក្តីសង្គ្រោះរបស់ពួកគេរួមមានទាំងដួងចិត្តដែលបានកែជាថ្មី ជីវិតដែលមានអំណាច និងលោកិយដែលបានផ្លាស់ប្រែ នោះគោលបំណងរបស់ទ្រង់ ហើយនិងរបស់ពួកគេ គឺពិតជាដំណឹងល្អហើយ។ ដំណឹងនេះ ល្អណាស់ដែលសូម្បីតែពួកទេវតាក៏ចង់បានដែរ ហើយយើងដែលស្រលាញ់ទ្រង់ដែលប្រទានដំណឹងល្អនេះក៏មានអំណរជាមួយនឹងការប្រកាសនេះផងដែរ (១ពេត្រុស ១:១០-១២)។ មិនថាយើងបានជាប់គុកខាងរូបកាយ សតិបញ្ញា ទំលាប់ កំហុស ទំនាក់ទំនង ឬក៏ស្ថានភាពក្តី ក៏ព្រះយេស៊ូវយាងមកដើម្បីសង្គ្រោះយើងចេញពីពួកវាអស់កល្បជានិច្ចដែរ។ នេះគឺជាដំណឹងដ៏អស្ចារ្យ ហើយវាគឺជាដំណឹងល្អ!

## *កំណត់*

១. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤)។

២. រឿងក្នុងផ្នែកនេះទាក់ទងនឹងផ្ទៃរឿងអំពី «ការបង្ក បង្កើតមនុស្សជាតិ» «ការធ្លាក់ចុះ» «ផែនការរបស់ព្រះ» «សេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទ» ហើយនិង «ការដែលព្រះអង្គរាប់ពួកមនុស្សមានបាបជាសុចរិត» នៅក្នុងសេចក្តីថ្លែងការណ៍អំពីសេចក្តីជំនឿរបស់ក្រុមចំរុះដំណឹងល្អ (The Gospel Coalition)។

៣. រឿងក្នុងផ្នែកនេះទាក់ទងនឹងផ្ទៃរឿងអំពី « អំណាចនៃព្រះវិញ្ញាណបរិសុទ្ធ» «នគររបស់ព្រះ» «មនុស្សថ្មីរបស់ព្រះ» «បុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ (មធ្យោបាយដែលព្រះអង្គប្រើដើម្បីប្រទានព្រះគុណ) និង «ការស្តារគ្រប់ទាំងអស់ឡើងវិញ» នៅក្នុងសេចក្តីថ្លែងសារភាពបាបរបស់ក្រុមចំរុះដំណឹងល្អ (The Gospel Coalition)។

៥. រឿងក្នុងផ្នែកនេះទាក់ទងនឹងផ្ទៃរឿងអំពី «តើយើងគួរទាក់ទងជាមួយនឹងវប្បធម៌នៅជុំវិញយើងយ៉ាងដូចម្តេច?» និង «តើអ្វីគឺជាព័ន្ធកិច្ចដែលផ្តោតលើដំណឹងល្អ?» នៅក្នុងនិមិត្តខាងទេវសាស្ត្រសំរាប់ព័ន្ធកិច្ចរបស់ក្រុមចំរុះដំណឹងល្អ (The Gospel Coalition)។